សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ណែនាំដោយ

លោក **ជួន ប៊ុនធី**

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **មូ ច័ន្ទវត្តី**

កញ្ញា **លាង សុវណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការរបស់អគ្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ណែនាំដោយ
លោក **ជួន ម៉ុនធី**

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **មូ ច័ន្ទវត្តី**
កញ្ញា **លាង សុវណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីររូបឈ្មោះ **មូ ច័ន្ទវត្តី** និង **លាខ សុវណ្ណា** ជានិស្សិតនីតិសាស្ត្រ ជំនាន់២៣ ក្រុម L4A1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២៣។

នាងខ្ញុំទាំងពីររូបសូមគោរពដឹងគុណ និងថ្លែងអំណរគុណដ៏វិសេសវិសាល ដែលមិនអាចប្រៀបផ្ទឹមបាន ដល់ **លោកឪពុកអ្នកម្ដាយ** ជាទីស្រឡាញ់របស់កូនៗ ដែលបានបង្កើតចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅដល់កូនៗប្រកបដោយព្រហ្មវិហារធម៌ទាំងបួន។ ជាពិសេសនៅពេលសម្រាកពីការងារ ទោះបីមានការនឿយហត់ ក៏ដោយ លោកទាំងពីរតែងតែផ្ដល់នូវសេចក្ដីស្រឡាញ់ ថ្នាក់ថ្នម យកចិត្តទុកដាក់ ថែមទាំងព្រួយបារម្ភគ្រប់ពេលពីសុខទុក្ខរបស់កូនៗជានិច្ច។ មិនយូរប៉ុន្មានដល់ពេលកូនៗ ចម្រើនវ័យត្រូវទទួលការអប់រំពីសាលា លោកទាំងពីរក៏បានបញ្ជូនកូនៗទៅសាលារៀន ដើម្បីទទួលបាននូវការអប់រំផ្នែកចំណេះដឹងទូទៅ ដោយមិនគិតពីការចំណាយចាយវាយទាំងឡាយ មិនត្រឹមតែប៉ុណ្ណោះលោកទាំងពីររឹតតែខិតខំទាំងកម្លាំងកាយចិត្ត ដោយភ្លេចការនឿយហត់ ដើម្បីទំនុកបម្រុងកូនៗឱ្យបានរៀនសូត្រក្រេបយកចំណេះដឹង។

នាងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យនាងខ្ញុំទាំងពីររូបបានចូលមកសិក្សានៅសាកលវិទ្យាល័យមួយនេះ និងជាពិសេស បានផ្ដល់ឱកាសដល់នាងខ្ញុំទាំងពីររូបបានចូលរួមក្នុងការសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

នាងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សាស្ត្រាចារ្យ ជួន ម៉ុនធី** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានយល់ព្រមក្នុងការដឹកនាំសារណារបស់នាងខ្ញុំទាំងពីររូបទាំងពីរ ជាពិសេសលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ផ្ដល់ដំបូន្មានល្អៗ លើកទឹកចិត្ត និងណែនាំដល់នាងខ្ញុំទាំងពីររូបឱ្យខិតខំប្រឹងប្រែងធ្វើកិច្ចការសារណានេះឱ្យទទួលបានជោគជ័យ។

ជាចុងក្រោយ នាងខ្ញុំទាំងពីររូបទាំងពីរសូមលើកហត្ថាប្រណមបួងសួងសុំដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះ សូមតាមជួយថែរក្សា លោកឪពុកអ្នកម្ដាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាស្ត្រាចារ្យ និងមិត្តភក្តិរួមជំនាន់ទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ព្រមទាំងទទួលបាននូវសុខសុភមង្គល ទទួលទានមានបានក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

នាងខ្ញុំទាំងពីររូបឈ្មោះ **បូ ច័ន្ទវត្តី** និង **លាង សុវណ្ណា** ជានិស្សិតនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់២៣។ នាងខ្ញុំទាំងពីរបានឆ្លងកាត់ការសិក្សា និងទទួលបានការបណ្តុះបណ្តាលលើជំនាញនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំមកហើយ លើសពីនេះទៅទៀត នាងខ្ញុំទាំងពីរជ្រើសរើសយកការសរសេរសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ព្រោះជាឱកាសដ៏ល្អសម្រាប់នាងខ្ញុំទាំងពីររូប នៅក្នុងការបង្កើតនូវស្នាដៃមួយដែលអាចបញ្ជាក់អំពីការខិតខំប្រឹងប្រែង ព្រមទាំងចំណេះដឹងដែលនាងខ្ញុំទាំងពីរទទួលបានពីការសិក្សាកន្លងមក។

ការសិក្សានៅថ្នាក់បរិញ្ញាបត្រនេះ នាងខ្ញុំទាំងពីររូបបានរៀនសូត្រនូវមុខវិជ្ជាជាច្រើន ដែលសុទ្ធសឹងតែទាក់ទងទៅនឹងជំនាញដែលនាងខ្ញុំទាំងពីររូបសិក្សា ក្នុងចំណោមមុខវិជ្ជាទាំងអស់ នាងខ្ញុំទាំងពីរមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ដែលជាមុខវិជ្ជាមួយនៅក្នុងចំណោមមុខវិជ្ជាដែលសំខាន់ៗដទៃទៀត ព្រមទាំងជាមុខវិជ្ជា ដែលបង្ហាញអំពីវិធានក្នុងការអនុវត្តទាក់ទងទៅនឹងដំណាក់កាលទាំងបួនក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយនាងខ្ញុំទាំងពីររូបក៏សម្រេចចិត្តជ្រើសរើសយកដំណាក់កាលចោទប្រកាន់មកធ្វើការសិក្សាស្រាវជ្រាវ។ ដូច្នេះ នាងខ្ញុំទាំងពីររូបបានជ្រើសរើសយកប្រធានបទស្តីអំពី **"ចំណាត់ការកិច្ចរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"** មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុដែលនាងខ្ញុំទាំងពីររូប ធ្វើការស្រាវជ្រាវទៅលើប្រធានបទនេះ ដោយសារដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយសំខាន់នៅក្នុងចំណោមដំណាក់កាលផ្សេងៗទៀត ដែលមានវត្តមានចៅក្រមអយ្យការ ដើរតួនាទីយ៉ាងសំខាន់ចំពោះការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលធ្វើឡើងតាមរយៈបណ្តឹងអាជ្ញា។ នាងខ្ញុំទាំងពីររូបសង្ឃឹមថា ស្នាដៃមួយនេះនឹងអាចចូលរួមចំណែកលើកស្ទួយចំណេះដឹងទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់អង្គការអយ្យការអមសាលាដំបូងតាមរយៈខ្លឹមសារដែលបានបកស្រាយ ជាពិសេសប្រធានបទនេះ អាចជាជំនួយដល់ប្អូនៗនិស្សិតច្បាប់ជំនាន់ក្រោយ ទុកជាឯកសារ ឬជាជំនួយស្មារតី ដល់ប្អូនៗក្នុងការស្រាវជ្រាវ ឬចង់ស្វែងយល់បន្ថែម។

យ៉ាងណាមិញ ការស្រាវជ្រាវលើប្រធានមួយនេះ គឺពិតជានៅមានចំណុចខ្វះខាត ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យហេតុនេះ សូមលោក លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត ព្រមទាំងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់នាងខ្ញុំទាំងពីររូបផង។ នាងខ្ញុំទាំងពីររូប មានសេចក្តីត្រេកអរយ៉ាងក្រៃលែង នៅក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីចូលរួមចំណែកក្នុងការកែលម្អ ឬកែប្រែនូវចំណុចខ្វះខាតក្នុងកិច្ចការស្រាវជ្រាវមួយនេះ ឱ្យកាន់តែមានអត្ថន័យខ្លឹមសារល្អប្រសើរថែមទៀត។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ................................................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃអង្គការអយ្យការអមសាលាដំបូង

**១.១. អង្គការអយ្យការអមសាលាដំបូង** ........................................ ៤

១.១.១. តើអង្គការអយ្យការជាអ្វី? ........................................ ៤

១.១.២. សមាសភាពអយ្យការអមសាលាដំបូង ........................................ ៦

**១.២. គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ** ........................................ ៧

១.២.១. គោលការណ៍ឋានានុក្រម ឬគោលការណ៍ឯកភាព ........................................ ៧

១.២.២. គោលការណ៍នៃភាពមិនអាចដាច់គ្នារបស់អង្គការអយ្យការ ឬគោលការណ៍អវិភាគ ........................................ ៨

១.២.៣. គោលការណ៍ឯករាជ្យរបស់អង្គការអយ្យការ ........................................ ៨

១.២.៤. គោលការណ៍នៃការមិនទទួលខុសត្រូវរបស់អង្គការអយ្យការ ........................................ ៩

១.២.៥. គោលការណ៍មិនអាចប្តឹងជំទាស់បាន ........................................ ១០

**១.៣. មុខការរបស់អង្គការអយ្យការអមសាលាដំបូង** ........................................ ១០

១.៣.១. សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា ........................................ ១០

១.៣.២. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ........................................ ១១

១.៣.៣. តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា ........................................ ១២

## ជំពូកទី២

## ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការអមសាលាដំបូង

**២.១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ** ........................................ ១៣

**២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ** ........................................ ១៣

២.២.១.ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តមិនមែនជាបទល្មើស ........................................ ១៣

២.២.១.១. ការខ្វះធាតុផ្សំនៃបទល្មើស ........................................ ១៤

២.២.១.២. អំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ........................................ ១៥

២.២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តជាបទល្មើស ........................................ ១៦

២.២.២.១. មូលហេតុគតិយុត្ត..............................................................................................................១៦
២.២.២.២. ការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ..................................................១៩
២.២.២.៣. បទល្មើសដែលមានព្យសនកម្មតិចតួច ............................................................................២៤
២.២.២.៤. ការមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើស ...................................................................២៤
**២.៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**..........................................................២៥
២.៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ .............................................................................២៥
២.៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ..........................................................................២៥
**២.៤. នីតិវិធីនៃការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ**..............២៥
២.៤.១. ការសើរើកែប្រែសេចក្ដីសម្រេចរបស់តំណាងអយ្យការ..............................................................២៦
២.៤.២. ការប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ..................................................................២៦
២.៤.៣. ការធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ ............................................... ២៧
២.៤.៤. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី...................................................................................... ២៧

## ជំពូកទី៣

## ការចោទប្រកាន់របស់អង្គការអយ្យការអមសាលាដំបូង

**៣.១. ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ**.......................................................................២៨
៣.១.១. លក្ខខណ្ឌនាំឱ្យមានការស៊ើបសួរ ..........................................................................................................២៩
៣.១.២. នីតិវិធីនៃការបើកការស៊ើបសួរ ...........................................................................................................៣០
៣.១.៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យបើកការស៊ើបសួរ ...................................................... ៣២
៣.១.៤. អានុភាពនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ............................................................................................ ៣២
**៣.២. ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់**.......................................................៣៣
៣.២.១. លក្ខខណ្ឌនាំឱ្យមានការបញ្ជូនទៅជំនុំជម្រះផ្ទាល់ .....................................................................៣៣
៣.២.២. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់..........................................................................................៣៥
៣.២.៣. ទម្រង់នៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..........................................................................................៣៧
៣.២.៤. អានុភាពនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ .......................................................................................៣៨
**៣.៣. ការចោទប្រកាន់តាមរយៈការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**..............................................៣៩
៣.៣.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម.................................................................................................................៣៩
៣.៣.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ................................................................................................................. ៤០

៣.៣.៣.អានុភាពនៃការបង្ហាញខ្លួនភ្លាម ............................................................................៤២
**សេចក្តីសន្និដ្ឋាន**...............................................................................................................៤៣
**អនុសាសន៍**.......................................................................................................................៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ប្រទេសកម្ពុជាបានចាប់ផ្តើមធ្លាក់ក្នុងសង្គ្រាមស៊ីវិលជាង ៣ ទសវត្សន៍ រហូតដល់ឆ្នាំ១៩៩៣ ក្រោមការចរចារក្នុងសន្ធិសញ្ញាទីក្រុងប៉ារីស ទើបព្រះរាជាណាចក្រកម្ពុជាទទួលបានសុខសន្តិភាពពិតប្រាកដ។ នៅក្នុងរយៈពេលជាង ៣ ទស្សវត្សន៍នេះ ព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់ ៥ សម័យកាលមក ក្រោមរូបភាពនៃសង្គ្រាមក្នុងស្រុកនេះបានធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធការគ្រប់គ្រងរដ្ឋមានការប្រែប្រួលទៅតាមសម័យកាល ដែលបានធ្វើឱ្យប្រព័ន្ធច្បាប់សំខាន់ៗ លែងមានអានុភាពក្នុងការគ្រប់គ្រងប្រទេសឱ្យប្រសិទ្ធភាព។ នៅក្នុងឆ្នាំ១៩៩៣ សន្ធិសញ្ញាទីក្រុងប៉ារីស បានធ្វើឱ្យប្រទេសកម្ពុជាចាប់ផ្តើមមកកើតរដ្ឋក្លាយជាព្រះរាជាណាចក្រកម្ពុជាទី២ រហូតដល់សព្វថ្ងៃនេះ។ ដើម្បីបង្ការមិនឱ្យមានភាពចលាចលក្នុងស្រុកម្តងទៀត និងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយក្នុងសង្គម រាជរដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការបង្កើតឡើងនូវច្បាប់សំខាន់ៗសម្រាប់គ្រប់គ្រងរដ្ឋ ប៉ុន្តែទោះបីជាមានច្បាប់សម្រាប់គ្រប់គ្រងរដ្ឋពិតមែនក៏មិនអាចគ្រប់គ្រងស្ថានភាពសង្គមបានដែរ ព្រោះមានការវិវត្តជារៀងរាល់ថ្ងៃ។ ក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩៣ ជាក្រមមួយ ពុំបានចែងឱ្យបានលម្អិត អំពីនីតិវិធីក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌនោះទេ ដែលធ្វើឱ្យមានភាពចន្លោះប្រហោងផ្នែកច្បាប់។

បច្ចុប្បន្នក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ត្រូវបានចែកចេញជា ១១គន្ថី និង៦១២ មាត្រា ដែលគន្ថីនីមួយៗមានការបែងចែកអំពី នីតិវិធី តួនាទី ភារកិច្ច របស់បុគ្គលដែលមានសមត្ថកិច្ចនៅក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ គន្ថីទី២ នៅរាល់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់គឺ ត្រូវតែមានស្ថាប័នមួយដែលតំណាងឱ្យសង្គម ឬតំណាងឱ្យរដ្ឋនៅក្នុងសាលាជម្រះក្តីនីមួយៗ ដើម្បីការពារផលប្រយោជន៍សាធារណៈក៏ដូចជាផលប្រយោជន៍ជាតិផងដែរនោះគឺ «អង្គការអយ្យការ»។ យ៉ាងណាមិញ តុលាការមានចៅក្រមជាអ្នកបំពេញមុខងារ ក្នុងនោះដែលមានតួនាទីវិនិច្ឆ័យក្តីសម្រេចសេចក្តីដោយផ្អែកលើច្បាប់ជាធរមាន ប៉ុន្តែស្ថាប័នអយ្យការ គឺមានព្រះរាជអាជ្ញា ដែលជាអ្នកបំពេញមុខងារក្នុងនោះមានតួនាទី និងភារកិច្ចធ្វើបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ ទាមទារឱ្យតុលាការសម្រេចសេចក្តី ហើយប្រកាសផ្តន្ទាទោសជនល្មើសតាមច្បាប់កំណត់ ដើម្បីឱ្យសង្គមជាតិមានសណ្តាប់ធ្នាប់ និងសន្តិសុខ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

អង្គការអយ្យការ គឺជាអង្គការសង្គម ដែលមានតួនាទីការពារសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ នៅក្នុងករណីប្រសិនបើមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង ព្រះរាជអាជ្ញា មានតួនាទីសំខាន់ជាងគេក្នុងការធ្វើបណ្តឹងអាជ្ញា ដើម្បីទាមទារឱ្យតុលាការអនុវត្តច្បាប់ដែលមានជាធរមាន។ ដើម្បីសិក្សាស្រាវជ្រាវឱ្យកាន់តែ

ស៊ីជម្រៅ ក៏ដូចជារំលេចឱ្យកាន់តែច្បាស់លាស់អំពីប្រធានបទនោះ ទើបមានចំណោទបញ្ហានៅត្រង់ថា តើអង្គការអយ្យការជាអ្វី? ហើយនៅដំណាក់កាលសាលាដំបូង តើអង្គការអយ្យការមានតួនាទី និងភារកិច្ចអ្វីខ្លះលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ **"ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"** នេះគឺចង់សិក្សាឱ្យកាន់តែស៊ីជម្រៅ ហើយកាន់តែលម្អិតទាក់ទងទៅនឹងចំណាត់ការរបស់អង្គការអយ្យការនៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌអមសាលាដំបូងរាជធានី-ខេត្ត។ ការសិក្សាស្រាវជ្រាវនេះ គឺនាងខ្ញុំទាំងពីររូបផ្តោតសំខាន់តែទៅលើតួនាទី និងភារកិច្ចរបស់អង្គការអយ្យការអមសាលាដំបូងតែប៉ុណ្ណោះ។ ម្យ៉ាងទៀត នាងខ្ញុំទាំងពីររូបសង្ឃឹមថា ការសិក្សាស្រាវជ្រាវលើប្រធានបទនេះនឹងក្លាយជាឯកសារសម្រាប់អ្នកសិក្សាទាំងឡាយយកទៅសិក្សាដើម្បីស្វែងយល់អំពីស្ថាប័នអយ្យការផង ឬជាឯកសារយោងទៅលើផ្នែកណាមួយដែលពាក់ព័ន្ធក្នុងការសិក្សាផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធាននេះ ត្រូវបានតាក់តែងឡើងដោយផ្អែកទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលនៅជាធរមាន ព្រមទាំងឯកសារច្បាប់នានាដែលទាក់ទិនទៅនឹងប្រធានបទមួយនេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **"ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"** ពិតជាមានសារៈសំខាន់ណាស់ ចំពោះដំណើរនៃការស្វែងយល់អំពីនីតិវិធីព្រហ្មទណ្ឌ ដោយសារតែដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយ ដែលស្មុគស្មាញក៏ដូចជាមានការស៊ើបអង្កេត និងស្វែងយល់អំពីធាតុផ្សំនៃបទល្មើសមុនធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ដែលទាក់ទងទៅនឹងអង្គហេតុដែលកើតមានឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើបទដ្ឋានគតិយុត្តជាតិ រួមមានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងនៅជាធរមាន ជាពិសេសច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីបកស្រាយទៅលើប្រធានបទ **"ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្ដីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"** នេះឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ថែមទៀតនោះ យើងនឹងសិក្សាទៅលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃអង្គការអយ្យការអមសាលាដំបូង** នៅក្នុងជំពូកនេះគឺបានរៀបរាប់អំពី៖ អង្គការអយ្យការ គោលការណ៍សំខាន់ៗ និងមុខការរបស់អង្គការអយ្យការ។

**ជំពូកទី២៖ ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការអមសាលាដំបូង** នៅក្នុងជំពូកនេះគឺបានរៀបរាប់អំពី៖ សញ្ញាណទូទៅ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ និងនីតិវិធីនៃការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ។

**ជំពូកទី៣៖ ការចោទប្រកាន់របស់អង្គការអយ្យការអមសាលាដំបូង** ចំពោះជំពូកចុងក្រោយនេះនឹងរៀបរាប់អំពី ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

# ជំពូកទី១
# សញ្ញាណទូទៅនៃអង្គការអយ្យការអមសាលាដំបូង

អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត គឺជាស្ថាប័នមួយសម្រាប់ធ្វើការចោទប្រកាន់រាល់រឿងក្តីព្រហ្មទណ្ឌ ដែលបានកើតឡើងនៅគ្រប់រាជធានី-ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងច្រើនរូបជាអ្នកតំណាងឱ្យស្ថាប័ននេះ។

ដើម្បីងាយស្រួល នៅក្នុងការសិក្សាស្វែងយល់អំពីចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូង ដូចដែលមាននៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺគប្បីយល់ដឹងផងដែរ ថាចំពោះការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ។ នៅពេលដែលមានអំពើមួយកើតឡើង ហើយត្រូវបានកំណត់ថាបទល្មើសនោះជាបទល្មើសព្រហ្មទណ្ឌ ហើយតែងតែឃើញមានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ចូលរួមក្នុងការស៊ើបអង្កេត ព្រមទាំងមានការចោទប្រកាន់ដែលតម្រូវឱ្យធ្វើឡើង ដោយតំណាងអយ្យការ។

## ១.១. អង្គការអយ្យការអមសាលាដំបូង

### ១.១.១. តើអង្គការអយ្យការជាអ្វី?

អយ្យការ មកពីពាក្យថា «អយ្យ» ជាពាក្យបាលី ដែលមានន័យដូចគ្នាទៅនឹងពាក្យ «អរិយ» ដែរ ប្រែមកថាអ្នកមានត្រកូលខ្ពង់ខ្ពស់ អ្នកដែលត្រូវគេគោរពកោតខ្លាច រីឯអយ្យការវិញ មានន័យថា ឈ្មោះច្បាប់មួយក្រមមានគតិសម្រាប់ចោទប្រកាន់ព្រមទាំងវិនិច្ឆ័យការផែនដី៖ ច្បាប់អយ្យការ ឬក្រមអយ្យការ។[1] និយមន័យតាមឬសគល់ដើមនៃពាក្យនេះ មានលក្ខណៈត្រូវគ្នាខ្លះដែរនឹងនិយមន័យគតិយុត្តត្រង់ សញ្ញាណ ដែលថា «សម្រាប់ចោទប្រកាន់» និង«អ្នកដែលត្រូវគេគោរពកោតខ្លាច» ព្រោះវាអាចទាក់ទងនឹងអំណាចរបស់អយ្យការក្នុងការចោទប្រកាន់ប្រឆាំងបទល្មើស ប៉ុន្តែអយ្យការគ្មានអំណាចវិនិច្ឆ័យសេចក្តីចេញជាសាលក្រមឡើយ។[2]

នៅអមសាលាជម្រះក្តីនីមួយៗ មានអង្គការអយ្យការដែលជាម្ចាស់នៃបណ្តឹងអាជ្ញា ហើយបណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅ ដោយអយ្យការ។ អង្គការអយ្យការ គឺជាស្ថាប័នមួយតំណាងឱ្យអង្គការនីតិប្រតិបត្តិ ការពារផលប្រយោជន៍របស់សង្គមទាំងក្នុងដំណាក់កាលស៊ើបសួរ ទាំងក្នុងដំណាក់កាលជំនុំជម្រះក្តី។ អង្គការអយ្យការ គឺជាអង្គការសង្គម ដែលមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ នៅពេលដែលស៊ើបអង្កេតឃើញអង្គហេតុណាមួយកើតឡើង ដែលជាបទល្មើសព្រហ្មទណ្ឌ នោះអយ្យការត្រូវធ្វើការចោទប្រកាន់

---

[1] យោងតាមវចនានុក្រមសម្តេចជួនណាត ត្រង់ពាក្យថា «អយ្យ»។

[2] រៀបរៀងដោយលោក ហេង ហៃផេង, វាក្យស័ព្ទគតិយុត្តអយ្យការ ៖ និយមន័យ និងសញ្ញាណសង្ខេប, ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨, http://salatraju.com/post/406, ថ្ងៃខែឆ្នាំចូលទស្សនានៅថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ២០២៣។

និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជនុំជម្រះនៅក្នុងប្រទេសកម្ពុជា។[3] មានន័យថា អង្គការអយ្យការ គឺមានសិទ្ធិនៅក្នុងការបង្រ្កាបបទល្មើសព្រហ្មទណ្ឌណាមួយដែលបានកើតឡើង ដើម្បីការពារផលប្រយោជន៍សាធារណៈក៏ដូចជាផលប្រយោជន៍ជាតិផងដែរ។

ការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ ហើយមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។[4] ដោយឡែក បណ្ដឹងអាជ្ញា គឺមានគោលបំណងពិនិត្យអត្ថិភាព (ភាពមាន) នៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាព (ភាពមានកំហុស) នៃជនល្មើស និងផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។[5] ចំពោះកម្មវត្ថុនៃបណ្ដឹងអាជ្ញា គឺបណ្ដឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវ័ន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាព ឯទៀតឡើយ។[6] ទៀតសោត អង្គការអយ្យការ ធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីការបង្គាប់ឱ្យចាប់ខ្លួន។

នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ទៀតសោត ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងក្ដីព្រហ្មទណ្ឌ។ ចៅក្រមអយ្យការជាអ្នកទទួលពាក្យបណ្ដឹងគ្រប់មជ្ឈដ្ឋានទាំងអស់ មានន័យថា កាលណាប្រជាពលរដ្ឋដាក់ពាក្យបណ្ដឹងក្ដី ឬមន្ត្រីនគរបាលយុត្តិធម៌ដាក់ពាក្យបណ្ដឹងក្ដី ឬមន្ត្រីរាជការសាធារណៈផ្សេងៗទៀតដែលបានដឹងពីបទល្មើសណាមួយ ហើយបានដាក់ពាក្យបណ្ដឹងមកកាន់ចៅក្រមអយ្យការផ្ទាល់បាន ពីព្រោះការដាក់ពាក្យបណ្ដឹង នេះអាចឆ្លងតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬស្ថាប័នអយ្យការផ្ទាល់។ នៅក្នុងពេលដែលចៅក្រមអយ្យការបានទទួលពាក្យបណ្ដឹងនោះ ចៅក្រមអយ្យការ ត្រូវធ្វើការត្រួតពិនិត្យពាក្យបណ្ដឹងជាមុនសិន ដោយធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់ ត្រូវពិនិត្យពាក្យបណ្ដឹងនោះឱ្យបានហ្មត់ចត់។

យ៉ាងណាមិញ ចៅក្រមអយ្យការអមសាលាដំបូងរួមមាន៖ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។[7] ព្រះរាជអាជ្ញាសំដៅដល់មន្ត្រីសាធារណៈ ដែលបម្រើការងារនៅក្នុងស្ថាប័នអយ្យការមានតួនាទីជាអ្នកដែលផ្ដួចផ្ដើមធ្វើបណ្ដឹងអាជ្ញា នៅក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌណាមួយ ទៅលើជនណាម្នាក់ឱ្យតុលាការផ្ដន្ទាទោសទៅតាមច្បាប់កំណត់។

---

[3] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥។

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៣១។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២ កថាខណ្ឌ២។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៨ ចំណុចទី៣។

### ១.១.២. សមាសភាពអយ្យការអមសាលាដំបូង

សមាសភាពអយ្យការអមសាលាដំបូង រួមមាន៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[8]

ព្រះរាជអាជ្ញា គឺជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗ នៃប្រទេសកម្ពុជា។ ចៅក្រមអយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗ ត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាចំនួនមួយរូប។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាតិដែលចូលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា រាល់ការធ្វើសកម្មភាពរបស់ខ្លួនក្នុងនាមជាតំណាងអយ្យការ។ ដោយឡែក ព្រះរាជអាជ្ញាមានតួនាទីក្នុងការទទួលខុសត្រូវលើការប្រព្រឹត្តទៅទាំងមូលរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានខ្លួនជាអ្នកតំណាង ជាហេតុនាំឱ្យព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវ ចំពោះការងាររបស់ខ្លួនផង និងការងាររបស់ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនទាំងអស់ផងដែរ។

អយ្យការអមសាលាដំបូងត្រូវដឹកនាំដោយព្រះរាជអាជ្ញា ០១ (មួយ) រូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូង ដែលខ្លួនបំពេញការងារ។[9] មានន័យថានូវរាល់អយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗ ត្រូវមានព្រះរាជអាជ្ញាតែមួយរូបប៉ុណ្ណោះដែលជាអ្នកតំណាង ប៉ុន្តែអាចមានព្រះរាជអាជ្ញារងជាច្រើនរូបដែលមិនអាចកំណត់ចំនួនមួយជាក់លាក់បានឡើយ ពោលគឺអាស្រ័យទៅតាមតម្រូវការការងារ និងស្ថានភាពចាំបាច់របស់ស្ថាប័ន។ ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[10] ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់។ មានន័យថា តួនាទីរបស់ព្រះរាជអាជ្ញារង គឺត្រូវបានចាត់តាំង និងបែងចែកដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។[11] រាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅឱ្យព្រះរាជអាជ្ញាត្រួតពិនិត្យជាមុនសិននៅមុនពេលសវនាការ។ ប្រសិនបើ ព្រះរាជអាជ្ញាមិនយល់ព្រមទៅលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏

---

[8] ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា២៩។

[9] ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣០ កថាខណ្ឌ២។

[10] ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣១ កថាខណ្ឌ១។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៨។

ចាត់តាំងខ្លួនឯងតែម្តងឱ្យធ្វើជាតំណាងអយ្យការក្នុងសវនាការនៃសាលាដំបូង។[12] ថ្វីដ្បិតតែ ព្រះរាជអាជ្ញារង មានសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិអំណាចទាំងអស់របស់ព្រះរាជអាជ្ញា ប៉ុន្តែសិទ្ធិអំណាចមួយចំនួននោះ ត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យ និងការសម្រេចរបស់ព្រះរាជអាជ្ញា។

នៅក្នុងដំណាក់កាលព្រះរាជអាជ្ញាបានបញ្ជាក់អំពីវត្តមានរបស់ក្រឡាបញ្ជី ហើយក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញា នៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌ ដែលមាននៅក្នុងបទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាដែលមានជាធរមាន។ ក្រឡាបញ្ជី គឺជាសមាសភាពមួយដែលអនុវត្តមុខងាររបស់ខ្លួននៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងអយ្យការអមសាលាដំបូង គឺមានក្រឡាបញ្ជីជាច្រើនរូបដែលជាលេខាធិការផ្ទាល់របស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៅក្នុងការបំពេញការងារទាំងផ្នែករដ្ឋបាល និងចំណាត់ការលើសំណុំរឿងឱ្យកាន់តែមានភាពងាយស្រួល។[13] ក្រឡាបញ្ជី ស្ថិតនៅក្រោមការបង្គាប់បញ្ជា និងដឹកនាំរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលខ្លួនស្ថិតនៅអមសម្រាប់កិច្ចការផ្នែកយុត្តាធិការ ហើយបំពេញមុខងារក្នុងរឿងរដ្ឋបាល និងចំណាត់ការទៅលើសំណុំរឿងក្តីដូចជា៖ ការធ្វើកំណត់ហេតុ ស្តាប់ចម្លើយរបស់ជនជាប់សង្ស័យ ឬជនល្មើស ឬដើមបណ្តឹង ឬសាក្សី ការធ្វើសេចក្តីព្រាងដីកា ឬសំណុំលិខិតផ្សេងៗសម្រាប់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ការចុះលេខសំណុំឯកសារ រក្សាទុកនូវសំណុំរឿង និងស្រាវជ្រាវរកនូវឯកសារផ្សេងៗទៀត។ ចំពោះសេចក្តីសម្រេច ក៏ដូចជាសេចក្តីសន្និដ្ឋានណាមួយដែលជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឱ្យបំពេញបានឡើយ។

## ១.២. គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

គោលការណ៍សំខាន់ៗ របស់អង្គការអយ្យការរួមមានជាអាទិ៍ ដូចខាងក្រោម៖

### ១.២.១. គោលការណ៍ឋានានុក្រម ឬគោលការណ៍ឯកភាព

អង្គការអយ្យការ គឺជាអង្គឯកភាព ដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គ

[12] ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣១ កថាខណ្ឌ២ វាក្យខណ្ឌ២ និង៣។
[13] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៣ កថាខណ្ឌ១។

ព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ទៀតសោត ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។[14]

### ១.២.២. គោលការណ៍នៃភាពមិនអាចដាច់គ្នារបស់អង្គការអយ្យការ ឬគោលការណ៍អវិភាគ

អង្គការអយ្យការ គឺជាអង្គអវិភាគ ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយ ដែលមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអង្គការអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[15]

គោលការណ៍នេះ គឺចង់សំដៅ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ចៅក្រមអយ្យការអាចជំនួសគ្នាបានជានិច្ច បានន័យថា នៅក្នុងរឿងក្តីមួយចាប់ផ្តើមដំបូងព្រះរាជអាជ្ញាចូលធ្វើការសន្និដ្ឋាន បន្ទាប់មកគាត់អាចឱ្យព្រះរាជអាជ្ញារងផ្លាស់ប្តូរគ្នាបាន។ ផ្តើមចេញពី គោលការណ៍នេះ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ត្រូវទទួលខុសត្រូវរួមគ្នា បានន័យថា បើព្រះរាជអាជ្ញារងធ្វើខុស គឺព្រះរាជអាជ្ញា ត្រូវតែទទួលខុសត្រូវចំពោះថ្នាក់លើរបស់គាត់។

### ១.២.៣. គោលការណ៍ឯករាជ្យរបស់អង្គការអយ្យការ

អង្គការអយ្យការ គឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីក្នុងករណី ដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួនដោយយកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះ ត្រូវអនុវត្តទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងៗទៀត។ ប៉ុន្តែ នៅសាលាជម្រះក្តី អាចលើកសំណើទៅនាយកឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។[16]

---

[14] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៧៥ ចំណុចទី១។

[15] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៧៥ ចំណុចទី២។

[16] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៧៥ ចំណុចទី៣។

គោលការណ៍នេះ មានន័យថា តុលាការគ្មានអំណាចត្រួតពិនិត្យទៅលើចៅក្រមអយ្យការទេ ចៅក្រមអយ្យការ មិនស្ថិតនៅចំណុះឱ្យតុលាការដែលខ្លួននៅអមឡើយ។ ផ្នែកខាងចៅក្រមអសនៈ ឬប្រធានតុលាការមិនអាចធ្វើការស្តីបន្ទោសទៅដល់ការចោទប្រកាន់ ឬសកម្មភាពការងាររបស់តំណាងអយ្យការបានទេ។ ប៉ុន្តែនៅក្នុងករណីខ្លះ តំណាងអយ្យការធ្វើខុសដែលមើលទៅជាករណីធ្ងន់ធ្ងរចៅក្រមអសនៈ ជាពិសេសប្រធានតុលាការអាចរាយការណ៍ទៅថ្នាក់លើនៃតំណាងអយ្យការ ប៉ុន្តែមិនអាចធ្វើការស្តីបន្ទោសផ្ទាល់បានទេ។

### ១.២.៤. គោលការណ៍នៃការមិនទទួលខុសត្រូវរបស់អង្គការអយ្យការ

ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាប្រើសិទ្ធិក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋនៅក្នុងការធ្វើការចោទប្រកាន់ទៅលើអង្គហេតុដែលកើតមានឡើងជាបទល្មើសព្រហ្មទណ្ឌ ដែលធ្វើឱ្យប៉ះពាល់ទៅដល់ប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម។ តាមគោលការណ៍ច្បាប់ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺអាចត្រូវបានទទួលនូវការច្រានចោលពីសំណាក់ ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ ក្នុងករណីអង្គហេតុនៃបទល្មើសដែលតំណាងអយ្យការបានចោទប្រកាន់នោះ ពិនិត្យទៅឃើញថា មិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនត្រូវចោទ ឬជនជាប់ចោទជាអាទិ៍។ ប្រសិនបើ ក្នុងករណីដែលមានការច្រានចោលការចោទប្រកាន់ពីសំណាក់ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ ដែលមានមូលហេតុដូចទៅនឹងការរៀបរាប់ខាងលើ តាមគោលការណ៍ព្រះរាជអាជ្ញាមិនទទួលខុសត្រូវរាល់ការខូចខាតដែលចេញពីសេចក្តីសម្រេចលើការចោទប្រកាន់របស់ខ្លួនទៅលើភាគីនៃរឿងក្តីព្រហ្មទណ្ឌ ជាពិសេសជនត្រូវចោទនៅក្នុងសំណុំរឿងនោះឡើយ។

យ៉ាងណាមិញ នៅក្នុងគោលការណ៍នេះ គឺមិនបានការពារព្រះរាជអាជ្ញាណាម្នាក់ ដែលប្រព្រឹត្តអំពើរបស់ខ្លួនទៅលើបទល្មើសព្រហ្មទណ្ឌណាមួយ នៅក្នុងករណីដែលការប្រព្រឹត្តនូវបទល្មើសនោះកើតចេញពីឆន្ទៈទុច្ចរិតរបស់ខ្លួន។[17] ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយព្រះរាជអាជ្ញានេះ អាចត្រូវបានចោទពីបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ត្រូវបានផ្អាកដោយស្វ័យប្រវត្តិមិនឱ្យបំពេញមុខងារជាបណ្តោះអាសន្ន រហូតដល់មានសេចក្តីសម្រេចរបស់តុលាការអំពីទោសជាស្ថាពរ។[18]

ដូច្នេះព្រះរាជអាជ្ញា ក៏ដូចជាតំណាងអយ្យការ គ្រប់រូបត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌនៅពេលដែលខ្លួនបានប្រព្រឹត្ត បទល្មើសព្រហ្មទណ្ឌណាមួយ នៅលើកិច្ចចោទប្រកាន់របស់គាត់ដូចដែលច្បាប់បានបញ្ញត្តិជាធរមាន។

[17] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៩៩។

[18] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៥៨ កថាខណ្ឌ១។

### ១.២.៥. គោលការណ៍មិនអាចប្ដឹងជំទាស់

តាមគោលការណ៍នៃច្បាប់ ចៅក្រម សំដៅដល់ចៅក្រមអាសនៈ រួមមានជាអាទិ៍ ចៅក្រមជម្រះក្ដី និង ចៅក្រមស៊ើបសួរ ប៉ុន្តែ អង្គចៅក្រម គឺសំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា។[19]

ប្រសិនបើ ភាគីម្ខាងនៅក្នុងរឿងក្ដីយល់ឃើញថាសមាសភាពជំនុំជម្រះ មិនអាចផ្ដល់ជូននូវយុត្តិធម៌ដល់ខ្លួនបានដោយសារមូលហេតុណាមួយ ភាគីនោះអាចធ្វើការស្នើសុំដើម្បីប្ដូរសមាសភាពជំនុំជម្រះបាន។ ប៉ុន្តែ នៅក្នុងករណីសំណុំរឿងក្ដីព្រហ្មទណ្ឌ រាល់ភាគីមិនអាចធ្វើការប្ដឹងជំទាស់ចំពោះព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ដែលជាតំណាងនៃអយ្យការអមសាលាដំបូងបានទេ ទោះបីជានៅក្នុងករណីដែលតំណាងអយ្យការ ជាសាច់ញាតិ ឬជាប់ពាក់ព័ន្ធទៅនឹងភាគីនៃបណ្ដឹងណាក៏ដោយ។ មូលហេតុ ដែលភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមិនអាចធ្វើការប្ដឹងជំទាស់ចំពោះតំណាងអយ្យការបាន គឺដោយហេតុថា ការធ្វើឡើងនូវរាល់ការចោទប្រកាន់របស់តំណាងអយ្យការគឺ ត្រូវធ្វើឡើងក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ មិនមែនជាការចោទប្រកាន់ដើម្បីផលប្រយោជន៍របស់ខ្លួនផ្ទាល់នោះទេ។ ការចោទប្រកាន់របស់តំណាងអយ្យការ មិនមានន័យថាបុគ្គលដែលត្រូវបានធ្វើការចោទប្រកាន់ ត្រូវទទួលនូវការផ្ដន្ទាទោសដូចទៅនឹងការចោទប្រកាន់របស់តំណាងអយ្យការឡើយ។ ដោយសារមូលហេតុទាំងអស់នេះហើយ ទើបព្រះរាជអាជ្ញា ក៏ដូចជាតំណាងអយ្យការមិនត្រូវបានចាត់ទុកថាជា កម្មវត្ថុនៃបណ្ដឹងជំទាស់បានឡើយ។ ម្យ៉ាងវិញទៀត បណ្ដឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ។[20]

## ១.៣. មុខការរបស់អង្គការអយ្យការអមសាលាដំបូង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ។[21]

### ១.៣.១. សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង ដោយសារតាមរយៈការស៊ើបអង្កេតទៅលើបទល្មើសព្រហ្មទណ្ឌនោះ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបានជាច្រើនទីកន្លែង ដែលពាក់ព័ន្ធទៅនឹងបទល្មើសនោះ ហើយព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចតាមដែនដីរួមមាន៖ ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស និងព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស។[22]

---

19 ច្បាប់ស្ដីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា៣។

20 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៥៦។

21 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៦។

22 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៩។

### ១.៣.២. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិ និងអំណាចរបស់ខ្លួនស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អំណាចជូនដល់ព្រះរាជអាជ្ញាអមសាលាដំបូង នៅក្នុងដំណាក់កាលនៃការចោទប្រកាន់ជាដំណាក់កាលមួយ ដែលព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកលើការផ្តល់ចំណាត់ការក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ។ យ៉ាងណាមិញ អំណាចអយ្យការនៅក្នុងដំណាក់កាលចោទប្រកាន់ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជូននៅអំណាចចំនួន ៣ រួមមាន៖ អំណាចលើមន្ត្រីនគរបាលយុត្តិធម៌ អំណាចបើកការស៊ើបអង្កេត និងអំណាចនៅក្នុងការចោទប្រកាន់។

**អំណាចលើមន្ត្រីនគរបាលយុត្តិធម៌៖** ព្រះរាជអាជ្ញាត្រូវប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណា ការអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ នៅក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញា អាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ។ ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។[23]

**អំណាចនៃការបើកការស៊ើបអង្កេត៖** ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេត ដោយធ្វើការត្រួតពិនិត្យទៅលើអង្គហេតុ និងធាតុផ្សំនៃបទល្មើសជាមុនសិន នៅក្នុងការសម្រេចចោទប្រកាន់ថាចំពោះអំពើណាមួយដែលជាបទល្មើស។ ដោយធ្វើការស្វែងរកភស្តុតាងនៅក្នុងការស៊ើបអង្កេត ទោះបីជាការស៊ើបអង្កេតជាក់ស្តែងក្តី ការស៊ើបអង្កេតបឋមក្តី។ ទៀតសោត ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។

**អំណាចនៅក្នុងការចោទប្រកាន់៖** ក្រៅពីអំណាចដឹកនាំសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ អំណាចនៃការបើកការស៊ើបអង្កេត ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញាឱ្យមានចលនា មានន័យថា ចោទប្រកាន់ពីបទល្មើសណាមួយដែលកើតមានឡើង។[24] នៅក្នុងនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា

[23] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៧។

[24] រៀបរៀងដោយលោក មីន សំអុល, មេរៀននីតិវិធីព្រហ្មទណ្ឌ, ទំព័រ២៩។

ចក្រកម្ពុជា អំណាចក្នុងការចោទប្រកាន់បានផ្តល់ជូនឱ្យព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿងក្តីព្រហ្មទណ្ឌ ដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការជ្រើសរើសនីតិវិធីចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ដែលត្រូវបានហៅថា **"ជម្រើសនៃការចោទប្រកាន់ ឬគោលការណ៍កាលានុវត្តភាពចោទប្រកាន់"** ហើយត្រូវបានបកស្រាយក្នុងជំពូកបន្ទាប់។

### ១.៣.៣. តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសំខាន់នៅក្នុងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយសារ ព្រះរាជអាជ្ញាជាអ្នកតំណាងឱ្យអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ចំពោះចំណាត់ការទៅលើរឿងក្តីព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាមានដូចជា ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលទៅលើអំពើនីត្យានុកូលភាពនៃការស៊ើបអង្កេត ពិនិត្យមើលការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌតួនាទីរបស់អង្គការអយ្យការគឺជាដំណាក់កាលមួយនៅក្នុងការចោទប្រកាន់ ពីព្រោះមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ប៉ុន្តែ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជម្រើសនៃការចោទប្រកាន់ដល់ព្រះរាជអាជ្ញា ដោយសារតែ ព្រះរាជអាជ្ញាជាអ្នកតំណាងឱ្យស្ថាប័ននេះ អាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ បន្ទាប់ពីព្រះរាជអាជ្ញាទទួលបាននូវពាក្យប្តឹង និងពាក្យបរិហារ ដែលជារឿងក្តីនៃបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយត្រូវបានទទួលដោយផ្ទាល់ពីជនរងគ្រោះ ឬដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបញ្ជូនមកព្រះរាជអាជ្ញា នៅក្នុងនោះព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា មានតួនាទីក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍ទូទៅត្រូវធ្វើការចោទប្រកាន់ ប្រសិនបើសំណុំរឿងនោះមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់។ នៅរាល់ចំណាត់ការរបស់ព្រះរាជអាជ្ញា ត្រូវតែជាចំណាត់ការ ដែលបទប្បញ្ញត្តិច្បាប់បានអនុញ្ញាត ឬស្របតាមការអនុវត្តនៅក្នុងស្រុក។ យ៉ាងណាមិញ ចៅក្រមអយ្យការ មានតួនាទីអនុវត្តទោសនៅពេលដែលមានសេចក្តីសម្រេចរបស់តុលាការបានក្លាយជាស្ថាពរ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់បន្ថែមពីតួនាទីរបស់អង្គការអយ្យការមួយចំនួនដូចជា៖ អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។[25]

ដោយឡែក នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌ។

---

[25] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧។

# ជំពូកទី២
# ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការអមសាលាដំបូង

## ២.១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

ព្រះរាជអាជ្ញាមានសិទ្ធិអំណាចនៅក្នុងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ ចំពោះជនទាំងឡាយណាដែលប្រព្រឹត្តបទល្មើសពិតមែន ប៉ុន្តែនៅក្នុងលក្ខខណ្ឌមួយចំនួនច្បាប់បានតម្រូវឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការបានផងដែរ។ នៅក្នុងស្ថានភាពខ្លះ ការចោទប្រកាន់របស់ព្រះរាជអាជ្ញាមិនមែនជាដំណោះស្រាយល្អនោះទេ ហើយក្នុងការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញានេះ ក៏មិនមែនមានន័យថារឿងក្ដីព្រហ្មទណ្ឌត្រូវបានបញ្ចប់នោះឡើយ។ ប្រសិនបើ បណ្ដឹងអាជ្ញាមិនទាន់រលត់ព្រះរាជអាជ្ញានៅតែមានសិទ្ធិក្នុងការសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍ និងសណ្ដាប់ធ្នាប់សាធារណៈជូនដល់សង្គមជាតិ។

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌតួនាទីរបស់អង្គការអយ្យការ គឺជាដំណាក់កាលមួយនៅក្នុងការចោទប្រកាន់ ពីព្រោះ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ ប៉ុន្តែ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់ជម្រើសនៃការចោទប្រកាន់ដល់ព្រះរាជអាជ្ញា ដោយសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ដូចនេះនាំឱ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ប្រកាន់យកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ មានន័យថា ទោះបីជាអំពើមួយជាបទល្មើសក៏ដោយ ប្រសិនបើពុំមានផលប្រយោជន៍ក្នុងការចោទប្រកាន់នោះទេ អាចនាំឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ ហេតុនេះខុសពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាមិនអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានទេ គឺនៅពេលដែលមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង នោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ជាដាច់ខាត។

## ២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការជានីតិវិធីមួយ ដែលព្រះរាជអាជ្ញាត្រូវតែអនុវត្តតាមច្បាប់ជាធរមាន។

### ២.២.១.ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តមិនមែនជាបទល្មើស

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលត្រូវផ្ដន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយជាកំហុសរបស់ចារីផ្ទាល់។ បទល្មើសព្រហ្មទណ្ឌ ក៏អាចត្រូវចាត់ទុកថាជាបាតុភូតអសកម្មក្នុងជីវភាពរស់នៅផងដែរ ពីព្រោះថាបទល្មើសបានជះឥទ្ធិពលអាក្រក់ដល់សណ្ដាប់ធ្នាប់សង្គមដល់សេរីភាពរបស់ពលរដ្ឋ។ ជាធម្មតា អាចចាត់ទុកអំពើមួយ គឺជាបទល្មើស លុះត្រាតែអំពើនោះបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់ការពារ។ ច្បាប់បញ្ញត្តិថា

អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម គឺជាបទល្មើស។[26] តាមន័យនេះ បង្ហាញឱ្យឃើញថាដើម្បីបង្កើតបានជាបទល្មើស គឺចាំបាច់ត្រូវតែមានច្បាប់ចែង ហើយមានតែអំពើដែលបង្កចលាចលដល់សង្គមប៉ុណ្ណោះ ដែលត្រូវចាត់ទុកជាបទល្មើស។

ច្បាប់ គឺជាកត្តាចាំបាច់បំផុតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ នេះគឺជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបានបង្កើតឡើង នៅក្នុងគោលបំណងការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការប្រព្រឹត្តអំពើផ្សេងៗ។ តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។[27] តាមន័យនេះ បង្ហាញថាដើម្បីអាចឱ្យគេចាត់ទុកថាអំពើណាមួយជាបទល្មើស លុះត្រាតែមានអត្ថបទច្បាប់បានចែងថាអំពើនោះគឺជាបទល្មើស មានអត្ថន័យយ៉ាងខ្លីថា គ្មានច្បាប់ចែង គ្មានបទល្មើសឡើយ។

មូលហេតុមាន ២ ដែលជាហេតុផលនាំឱ្យមាន ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តមិនមែនជាបទល្មើសគឺៈ ការខ្វះធាតុផ្សំនៃបទល្មើស និងអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ។

### ២.២.១.១. ការខ្វះធាតុផ្សំនៃបទល្មើស

យោងតាមគោលការណ៍ឯកកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[28]

បទល្មើសមានធាតុផ្សំ ៣ យ៉ាងគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈ និងធាតុផ្សំអត្តនោម័ត។ មានមតិខ្លះបានលើកឡើងថា ធាតុផ្សំនៃបទល្មើសមានតែពីរប៉ុណ្ណោះ ពោលគឺធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត ចំណែកឯធាតុផ្សំនីត្យានុកូល គឺស្ថិតនៅក្រៅបទល្មើស។ ជាការពិត ច្បាប់ពុំមែនជាធាតុផ្សំនៃបទល្មើសទេ គឺជារឿងហេតុ ឬសកម្មភាពប្រព្រឹត្ត និងចេតនារបស់ចារីដែលរួមផ្សំបង្កើតបានជាបទល្មើស។ ទោះជាយ៉ាងណាក្តី ជាធម្មតា យើងនៅតែអាចកំណត់បានថា បទល្មើសរួមមានធាតុផ្សំបីយ៉ាង ដោយចាប់ផ្តើមពីធាតុផ្សំនីត្យានុកូល ដែលជាប្រភពផ្ទាល់ក្នុងការបញ្ជាក់ថាអំពើមួយជាបទល្មើសរួមទាំងធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តផងដែរ។[29]

ធាតុផ្សំនីត្យានុកូល គឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ ចំពោះធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈ គឺជាសកម្មភាពក្នុងការប្រព្រឹត្តអំពើស្តែងចេញមកខាងក្រៅ ហើយអំពើនោះបានបង្កចេញជាព្យសនកម្ម ដែលជា

[26] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា២ វាក្យខណ្ឌ១។
[27] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣ កថាខណ្ឌ១។
[28] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា២៤។
[29] រៀបរៀងដោយលោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, មេរៀននីតិព្រហ្មទណ្ឌទូទៅ, ទំព័រ១០៨។

ទំនាក់ទំនងហេតុ និងផល អំពើ និងបច្ច័យ។ ចំពោះធាតុផ្សំអត្តនោម័ត គឺជាផ្នែកខាងក្នុង ឬកិរិយាផ្លូវចិត្តរបស់ជនល្មើស ចំពោះអំពើល្មើសដែលខ្លួនបង្កឡើង។ ប្រសិនបើ គ្មានចេតនាប្រព្រឹត្ត ច្បាប់បានបញ្ញត្តិថាគ្មានបទល្មើសទេ ប៉ុន្តែ នៅក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតឡើងចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។[30] ទោះបីជាជនល្មើសពុំមានចេតនាក្នុងការប្រព្រឹត្តក៏ដោយ តែបើអំពើនោះកើតឡើងដោយអចេតនា ការជឿជាក់ ឬការធ្វេសប្រហែស នោះក៏ត្រូវទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបង្កើតឡើងដែរ។

ដូច្នេះប្រសិនបើ អំពើណាមួយកើតឡើងមិនបានបំពេញនូវធាតុផ្សំទាំងបីនោះទេ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់នូវបទល្មើសនោះបានទេ ត្រូវចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ២.២.១.២. អំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ

តាមការពិតទៅ មិនមែនមានតែបទល្មើសព្រហ្មទណ្ឌទេ ដែលបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម គឺនៅមានអំពើមួយចំនួនទៀតដែលជាអំពើបង្កឱ្យមានគ្រោះថ្នាក់ដែរ ក៏ប៉ុន្តែ មិនបានត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទេ តែត្រូវបានចាត់ទុកថាជាកំហុសរដ្ឋប្បវេណី (បទល្មើសរដ្ឋប្បវេណី) ហើយចារីនឹងត្រូវចាប់បង្ខំឱ្យបង់ជាប្រាក់សំណង និងជំងឺចិត្តតែប៉ុណ្ណោះ។[31]

យោងតាមបទប្បញ្ញត្តិច្បាប់ បណ្តឹងរដ្ឋប្បវេណី គឺមានគោលបំណងធ្វើឱ្យទទួលបានការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្ម (ការខូចខាត) ដែលខ្លួនបានទទួលរង។[32] បណ្តឹងរដ្ឋប្បវេណីអាចយកមកសម្រេចបាន លុះត្រាតែតុលាការព្រហ្មទណ្ឌបានដោះស្រាយរឿងក្តីព្រហ្មទណ្ឌចប់សព្វគ្រប់ជាមុនសិន។[33]

ដោយឡែក នៅក្នុងករណីខ្លះទោះបីជាតុលាការព្រហ្មទណ្ឌសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ក៏ដោយ ក៏តុលាការរដ្ឋប្បវេណីអាចសម្រេចឱ្យចារីសងជាសំណងរដ្ឋប្បវេណីដែរ ប្រសិនបើតុលាការរកឃើញថា មានអំពើល្មើសផ្នែករដ្ឋប្បវេណីដែលជាមូលហេតុបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ ក៏ប៉ុន្តែអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌតាមន័យនៃច្បាប់ព្រហ្មទណ្ឌឡើយ។ **ឧទាហរណ៍៖** បុរស **ក** បានគ្រវែងចោលវត្ថុរឹងមួយទៅត្រូវនឹងរថយន្តរបស់អ្នកជិតខាង ដែលធ្លាប់មានទំនាស់ជាមួយខ្លួន និងបណ្តាលឱ្យរថយន្តនោះខូចខាត។ បន្ទាប់មក ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់បុរស **ក** ពីបទធ្វើឱ្យខូចខាតដោយចេតនា បន្ទាប់

---

[30] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤។

[31] រៀបរៀងដោយលោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, មេរៀននីតិព្រហ្មទណ្ឌទូទៅ, ទំព័រ២៣។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២ កថាខណ្ឌ៣។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៣។

ពីមានពាក្យបណ្ដឹងពីជនរងគ្រោះ។[34] ក្រោយពីការជំនុំជម្រះ រួចមក តុលាការបានសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ដោយសារតែកង្វះធាតុផ្សំអត្តនោម័ត ពោលគឺជនជាប់ចោទពុំមានចេតនាទុច្ចរិតធ្វើឱ្យខូចខាតរថយន្តរបស់ជនរងគ្រោះឡើយ បានសេចក្ដីថា បុរស **ក** បានគ្រវែងចោលវត្ថុរឹងពីក្នុងផ្ទះរបស់ខ្លួនចេញមកក្រៅ ដោយសារតែគាត់ខឹងសម្បាជាមួយប្រពន្ធគាត់ ហើយគាប់ជួនពេលនោះអ្នកជិតខាង(ជនរងគ្រោះ)ក៏បានបើករថយន្តមកដល់។ ការធ្វើឱ្យខូចខាត ដោយអចេតនាបែបនេះ ពុំមែនជា បទល្មើសព្រហ្មទណ្ឌឡើយ ហេតុដូច្នេះ តុលាការព្រហ្មទណ្ឌក៏បានសម្រេចសេចក្ដី ឱ្យជនជាប់ចោទរួចខ្លួនពីការចោទប្រកាន់។ ប៉ុន្តែ តុលាការរដ្ឋប្បវេណីនៅតែអាចដាក់ទណ្ឌកម្ម ដោយនឹងតម្រូវឱ្យជនប្រព្រឹត្តល្មើសបង់ប្រាក់សំណងនៃការខូចខាតរថយន្តដល់ជនរងគ្រោះបានជាដដែល ដោយផ្អែកលើកំហុសផ្នែករដ្ឋប្បវេណីដែលហៅថា **អំពើអនីត្យានុកូល**។

### ២.២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តជាបទល្មើស

កាលណាបទល្មើសព្រហ្មទណ្ឌត្រូវបានកើតឡើង មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ប៉ុន្តែស្របតាមកាលៈទេសៈខ្លះចំពោះការប្រព្រឹត្តបទល្មើស ហេតុ និងបច្ច័យនៃបទល្មើសគ្រាន់តែបង្កើតព្យសនកម្មតិចតួច មិនមានផលប្រយោជន៍ក្នុងការចោទប្រកាន់ នោះព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលប្រព្រឹត្តជាបទល្មើសរួមមាន៖ មូលហេតុគតិយុត្ត ការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ បទល្មើសដែលមានព្យសនកម្មតិចតួច និងមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើសបាន។

#### ២.២.២.១. មូលហេតុគតិយុត្ត

ច្បាប់បានបញ្ញត្តិ នៅក្នុងការរារាំងមិនឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ ទោះបីជាអំពើដែលកើតឡើងនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។ មូលហេតុគតិយុត្តរួមមាន៖

**អភ័យឯកសិទ្ធិ៖** មូលហេតុនៃការមិនដាក់ទោស ដោយសារតែស្ថានភាពពិសេសរបស់ចារី នៃបទល្មើស នៅពេលបានប្រព្រឹត្តបទល្មើសនោះ ដែលជាហេតុនាំឱ្យការចោទប្រកាន់ពីបទល្មើសមិនអាចធ្វើទៅបានឡើយ។ **ឧទាហរណ៍៖** អភ័យឯកសិទ្ធិគ្រួសារ មិនអាចត្រូវផ្ដន្ទាទោសព្រហ្មទណ្ឌបានទេ អំពើលួចទ្រព្យសម្បត្តិដែលបានប្រព្រឹត្តដោយបុព្វញាតិ ឬបច្ឆាញាតិ ឬអំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ។[35]

**អនិយ័តភាពនៃកិច្ចនីតិវិធី៖** ភាពដែលមិនស្របតាមបទប្បញ្ញត្តិច្បាប់ នៃការអនុវត្តកិច្ចនីតិវិធីនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងតំណាងអយ្យការ។ **ឧទាហរណ៍៖** ការចាប់ផ្ដើមធ្វើការ

[34] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤១០។
[35] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៥៥។

ឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ដោយតាមកិច្ចនីតិវិធីច្បាប់ការផ្តើមធ្វើការឆែកឆេរ មិនអាចធ្វើឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ លើកលែងតែករណីពិសេស។[36]

**ការរលត់នៃបណ្តឹងអាជ្ញា៖** មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ៖[37]

- មរណភាពនៃជនល្មើស៖ កាលណាជនល្មើស ដែលកំពុងស្ថិតក្នុងបណ្តឹងអាជ្ញាមួយ ហើយជននោះបានទទួលមរណភាពនឹងនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងតែមានលើជននោះត្រូវរលត់ ហើយដំណើរការទាំងឡាយនៃកិច្ចនីតិវិធីនឹងត្រូវបិទបញ្ចប់។ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជននោះបាន ប្រសិនបើជននោះទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ថ្វីដ្បិតតែបណ្តឹងអាជ្ញារលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ។[38]
- ការផុតអាជ្ញាយុកាល៖ អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលនៅពេលផុតចិរវេលានេះ ព្រះរាជអាជ្ញាពុំអាចនឹងធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបានឡើយ។ ចំពោះចិរវេលានៃអាជ្ញាយុកាល គឺប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖ ១៥ (ដប់ប្រាំ) ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ (ប្រាំ) ឆ្នាំចំពោះបទមជ្ឈិម ១ (មួយ) ឆ្នាំចំពោះបទលហុ។[39] ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើសចាប់ផ្តើមរាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ។ ក្រៅពីបទប្បញ្ញត្តិខាងលើនេះ គួរកត់សម្គាល់ថា បទល្មើសដែលមានចែងនៅមាត្រា៩ ក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ មិនអាចផុតរលត់អាជ្ញាយុកាលឡើយ។
- ការលើកលែងទោសជាទូទៅ៖ ការលើកលែងទោសជាទូទៅ ខុសពីកាលលើកលែងទោសដោយរាជានុសិទ្ធិរបស់ព្រះមហាក្សត្រដែលមានចែងនៅក្នុងច្បាប់ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗ។ បណ្តឹងអាជ្ញាមួយអាចនឹងត្រូវរលត់តាមរយៈការលើកលែង

---

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៩១។
[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៧។
[38] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥។
[39] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១០។

ទោសជាទូទៅ ដែលការលើកលែងទោសនេះ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភា សម្រាប់លើកលែងទោសជាទូទៅ ដែលនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីនឹងត្រូវរលត់។[40]

- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ៖ បណ្តឹងអាជ្ញាមួយត្រូវបានធ្វើឡើងតាមរយៈនៃការចោទប្រកាន់របស់តំណាងអយ្យការនៅក្នុងបទល្មើសព្រហ្មទណ្ឌណាមួយ ប៉ុន្តែដោយហេតុថា បទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវបាននិរាករណ៍ដោយមានច្បាប់ព្រហ្មទណ្ឌថ្មី ហេតុនេះបណ្តឹងអាជ្ញា ដែលធ្វើឡើងដោយឈរលើមូលដ្ឋាននៃបទល្មើសដែលមានចែងក្នុងច្បាប់ចាស់នឹងត្រូវរលត់។
- អាជ្ញាអស់ជំនុំ៖ ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែល ទោះបីក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[41] **ឧទាហរណ៍**៖ លោក **ក** បានចាក់ជនរងគ្រោះម្នាក់នឹងកាំបិតកាលពីឆ្នាំ២០១៨។ លោក **ក** ត្រូវបានតុលាការផ្តន្ទាទោសពីបទហិង្សាដោយចេតនា ឱ្យជាប់ពន្ធនាគាររយៈពេល ១ (មួយ) ឆ្នាំ។ បន្ទាប់ពីការផ្តន្ទាទោសបានចូលជាស្ថាពរ ជនរងគ្រោះក៏បានស្លាប់បាត់បង់ជីវិត ដោយសារតែស្នាមរបួសមានលក្ខណៈធ្ងន់ធ្ងរពេកមិនអាចនឹងព្យាបាលឱ្យជាសះស្បើយបាន។ ទោះជាយ៉ាងនេះក្តី លោក **ក** មិនអាចត្រូវបានចោទប្រកាន់ម្តងទៀតទេពី «បទឃាតកម្ម» ចំពោះអំពើដែលបានកើតឡើងកាលពីឆ្នាំ២០១៨ ឡើយ។

**មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា**៖ កាលណាច្បាប់ដោយឡែក បានចែងដោយជាក់លាក់នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរដូចជា៖[42]

- ការសម្របសម្រួលជាមួយរដ្ឋ ៖ **ឧទាហរណ៍**៖ នៅក្នុងករណី គ្រោះថ្នាក់ចរាចរណ៍បុកបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ ឬរបាំងបែងចែកទ្រូងផ្លូវ ដែលជនប្រព្រឹត្តនោះធ្វើការសម្របសម្រួលជាមួយរដ្ឋដោយព្រមសងការខូតខាតទាំងអស់។
- ការដកពាក្យប្តឹង៖ នៅក្នុងករណី ដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។ **ឧទារហរណ៍**៖ ចាត់ទុកដូចជាការដកពាក្យប្តឹង ដោយជនរងគ្រោះដែរ ករណីដែលមានការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះ ជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង

[40] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៩០ កថាខណ្ឌ៤។
[41] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២។
[42] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៨។

ជាថ្មីម្តងទៀត ដែលល្មើសនឹងច្បាប់ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញានោះទៅតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីសំណាក់ជនរងគ្រោះម្តងទៀតក៏ដោយ។[43]

– ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។ **ឧទាហរណ៍៖** ករណីបទល្មើសព្រៃឈើ បទល្មើសពន្ធដារជាអាទិ៍។

### ២.២.២.២. ការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ

ការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើដែលប្រព្រឹត្តជាបទល្មើសរួមមាន៖

**វិបល្លាសស្មារតី៖** វិបល្លាសស្មារតី សំដៅលើវិបត្តិដែលធ្វើឱ្យមានភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួនជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[44] ដើម្បីធ្វើឱ្យវិបល្លាសស្មារតីក្លាយទៅជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌទាំងស្រុង នោះចាំបាច់ត្រូវបញ្ជាក់ដោយភស្តុតាងថា ជាវិបល្លាសដែលបានបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការយល់ដឹងរបស់ជនណាម្នាក់ប្រព្រឹត្តបទល្មើស ឬបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការត្រួតត្រាសកម្មភាពរបស់ខ្លួន។ ប្រសិនបើជនណាម្នាក់ប្រព្រឹត្តបទល្មើសមានវិបល្លាសស្មារតី ដែលមានអានុភាពត្រឹមតែបន្ថយនូវការយល់ដឹងខុសត្រូវរបស់ខ្លួនតែប៉ុណ្ណោះ ជននោះនៅតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែស្ថានភាពបែបនេះតុលាការត្រូវគិតគូរពីបញ្ហានេះកាលបើតុលាការកំណត់ទោស។[45]

**អានុភាពកម្លាំង ឬការបង្ខំ៖** វិបល្លាសស្មារតី បានលុបចោល ឬបានធ្វើឱ្យខូចខាតដល់ការយល់ដឹងរបស់ជនដែលប្រព្រឹត្តបទល្មើស រីឯកម្លាំង ឬការបង្ខំ វិញបានលុបចោលនូវឆន្ទៈរបស់ជនដែលប្រព្រឹត្តបទល្មើសតែម្តង ហើយមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[46] តាមក្រមព្រហ្មទណ្ឌមិនបានឱ្យនិយមន័យលើពាក្យ អានុភាពនៃកម្លាំង និងការបង្ខំឡើយ។ ចំណែកឯ ក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជាវិញ មិនបានប្រើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំទេ ក៏ប៉ុន្តែចែងអំពីកម្លាំងបង្ខំ នៅត្រង់មាត្រា៩៦ កាលបើមានភស្តុតាងថា មានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឱ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះ កាលមិនអាចទប់ទល់នឹងកម្លាំងនោះបានទេក៏ប្រព្រឹត្តបទល្មើសនោះទៅ។ ជនប្រព្រឹត្តបទ

[43] ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, នស/រកម/១០០៥/០៣១, ២៤ តុលា ឆ្នាំ២០០៥, មាត្រា៣៦។

[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣១ កថាខណ្ឌ១។

[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣១ កថាខណ្ឌ២។

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៦។

ល្មើសនេះ មិនត្រូវឱ្យទទួលខុសចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ។ មួយវិញទៀត មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់បានឱ្យនិយមន័យនៃពាក្យ កម្លាំងបង្ខំ ថាជាគ្រោះថ្នាក់ណាមួយដែលបណ្ដាលឱ្យមានអាសន្នយ៉ាងធំបំផុត។ ពាក្យថា អាសន្នយ៉ាងធំបំផុត បានសេចក្ដីថា គ្រោះថ្នាក់យ៉ាងធំបំផុត ដែលនឹងត្រូវធ្លាក់មកលើខ្លួនក្នុងពេលជាបន្ទាន់ក្រៃពេកមិនអាចឱ្យខ្លួនចៀសផុតពីគ្រោះថ្នាក់នេះបាន ដោយមិនបានប្រព្រឹត្តបទល្មើសមួយនោះទេ ម្យ៉ាងទៀតគ្រោះថ្នាក់នោះ កាលបើកើតមានឡើងក៏មិនមែនកើតមកពីឆន្ទៈផ្ទាល់របស់ជនដែលប្រព្រឹត្តបទល្មើសនោះដែរ និងមិនមែនជនប្រព្រឹត្តបទល្មើសនោះជាអ្នកបង្កើត ឬជាអ្នកបណ្ដាលឱ្យមានគ្រោះថ្នាក់នោះដែរ។ ថ្វីដ្បិតតែ ក្រមព្រហ្មទណ្ឌបច្ចុប្បន្នមិនបានឱ្យនិយមន័យជាក់លាក់លើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំក៏ដោយ ក៏ខ្លឹមសារនៃមាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ មិនខុសប្លែកពីខ្លឹមសារនៃមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌចាស់ដែរ។ ហេតុនេះ ការឱ្យនិយមន័យនៃពាក្យ កម្លាំងបង្ខំ ក្នុងមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់អាចជាប្រទីបបំភ្លឺមួយសម្រាប់ស្វែងយល់ពីមាត្រា៣៦នៃក្រមព្រហ្មទណ្ឌបាន។ អានុភាពនៃកម្លាំង ឬការបង្ខំ គឺជាមូលហេតុអត្តនោម័តនៃការរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ។

**ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ៖** បុគ្គលណាដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះខុសច្បាប់យ៉ាងជាក់លាក់។ កាលបើអំពើប្រព្រឹត្តត្រូវគ្នានឹងធាតុផ្សំនៃបទល្មើសធ្ងន់ធ្ងរយ៉ាងខ្លាំងដែលរួមមាន បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសំអាងទៅលើបញ្ជារបស់អាជ្ញាធរស្របច្បាប់ឡើយ។[47]

- ការអនុញ្ញាតដោយច្បាប់៖ នៅក្នុងករណីដែលច្បាប់បញ្ញត្តិ ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើណាមួយ ហើយច្បាប់មិនបញ្ញត្តិឱ្យផ្ដន្ទាទោសទៅលើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចនោះទេ ជនដែលអនុវត្តសិទ្ធិតាមច្បាប់ ត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ **ឧទាហរណ៍៖** ចៅក្រមដែលសម្រេចសេចក្ដីផ្ដន្ទាទោសលើជនណាម្នាក់ដាក់ពន្ធនាគារ គឺជាអំពើសត្យានុម័តនៃការបង្ខាំងមនុស្ស ប៉ុន្តែអំពើនេះមិនត្រូវបានចាត់ទុកថាជាបទល្មើសទេ ពីព្រោះថាការសម្រេចសេចក្ដីបែបនេះធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាចៅក្រមតែប៉ុណ្ណោះ។
- ការអនុញ្ញាតដោយអាជ្ញាធរ៖ ការអនុញ្ញាតដោយអាជ្ញាធរ ជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែអាជ្ញាធរនោះ គឺជាអាជ្ញាធរស្របច្បាប់ និងជាអ្នកចេញបញ្ជាស្របច្បាប់។

[47] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣២។

អាជ្ញាធរស្របច្បាប់ សំដៅទៅលើអាជ្ញាធរសាធារណៈ ដែលអាចជាអាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត។ តាមក្រមព្រហ្មទណ្ឌ មិនអនុញ្ញាតឱ្យជនដែលបានប្រព្រឹត្តបទល្មើសតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ រួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌបានឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ចំពោះពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ទាមទារឱ្យមានការវាយតម្លៃទៅតាមករណីនីមួយៗ ដោយត្រូវពិនិត្យទៅលើស្ថានភាព និងកាលៈទេសៈជាក់ស្ដែងរបស់អ្នកទទួលបញ្ជាដូចជា សមត្ថភាព បទពិសោធន៍ និងឋានៈ ជាដើម។ ដូច្នេះ មន្ត្រីរាជការថ្នាក់ខ្ពស់មានសមត្ថភាពអាចធ្វើការវាយតម្លៃកំណត់អំពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃបញ្ជាណាមួយរបស់ថ្នាក់លើខ្លួនបានច្រើនជាងមន្ត្រីធម្មតា ឬជនសាមញ្ញដែលត្រូវបានអាជ្ញាធរបញ្ជាឱ្យធ្វើអ្វីមួយ។ ការប្រើពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់នាំឱ្យសន្និដ្ឋានបានថា ប្រសិនបើអំពើដែលប្រព្រឹត្តគ្រាន់តែជាអំពើខុសច្បាប់ ប៉ុន្តែមិនមែនជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ទេ អ្នកប្រព្រឹត្តតាមបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន។ **ឧទាហរណ៍៖** នៅក្នុងពេលស្ដាប់ចម្លើយជនសង្ស័យដែលត្រូវបានឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ម្នាក់បានបញ្ជាឱ្យមន្ត្រីក្រោមឱវាទរបស់ខ្លួនវាយតប់ និងធ្វើទារុណកម្មលើជនសង្ស័យដើម្បីទទួលបានចម្លើយសារភាព។ ថ្វីត្បិតតែ មន្ត្រីនគរបាលអាចឃាត់ខ្លួនអ្នកដទៃបានក៏ពិតមែន ក៏ប៉ុន្តែ ច្បាប់បានហាមឃាត់យ៉ាងច្បាស់លាស់ពីការប្រើអំពើហិង្សា។ ដូច្នេះ អំពើបែបនេះ គឺជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[48]

**ការពារស្របច្បាប់៖** មិនឱ្យបុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ នៅក្នុងលក្ខខណ្ឌនៃការការពារស្របច្បាប់ដូចតទៅ៖ បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ ហើយបទល្មើសនឹងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[49] ទៀតសោត ការការពារស្របច្បាប់ គឺជាអំពើរបស់បុគ្គលណាម្នាក់ ដែលបន្ទាប់ពីបានរងនូវការឈ្លានពានដោយអយុត្តិធម៌ ក៏ធ្វើការតបតភ្លាមៗចាំបាច់ដើម្បីការពារខ្លួន ឬអ្នកដទៃ ឬក៏ការពារទ្រព្យសម្បត្តិណាមួយ ហើយមានលក្ខណៈសមាមាត្រទៅនឹងអំពើឈ្លានពាន។ តាមក្រមព្រហ្មទណ្ឌ ការការពារស្របច្បាប់ គឺជាយុត្តិកម្មនៃបទល្មើស ឬក៏ជាមូលហេតុសត្យានុម័តនៃការរួចផុតពី

[48] រៀបរៀងដោយលោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, មេរៀននីតិព្រហ្មទណ្ឌទូទៅ, ទំព័រ៣៣។

[49] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៣។

ការទទួលខុសត្រូវនូវបទល្មើសព្រហ្មទណ្ឌ។ **ឧទាហរណ៍៖** ដើម្បីទប់ទល់នឹងជនម្នាក់ដែលមានបំណងចង់សម្លាប់រូបខ្លួន បុរសម្នាក់បានវាយជនល្លានពាននោះបណ្ដាលឱ្យមានរបួស។ អំពើរបស់បុរសម្នាក់នេះ គឺជាការការពារស្របច្បាប់ ពោលគឺបុរសម្នាក់នេះ រួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ដោយសារតែអំពើបង្កឱ្យមានរបួសដល់ជនដែលបានល្លានពានមករូបគាត់ជាមុននោះ គាត់ក៏បានតបតភ្លាមៗ។

**សច្ចធារណ៍នៃការការពារស្របច្បាប់៖** ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖ បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សរស់នៅ។ បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។ ប៉ុន្តែ សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ដោយសច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយបាន។[50] នៅក្នុងករណី ដែលមានសច្ចធារណ៍នៃការការពារស្របច្បាប់ បុគ្គលដែលបានប្រព្រឹត្តបទល្មើសគ្រាន់តែបង្ហាញភស្តុតាង អំពីស្ថានភាពសច្ចធារណ៍នៃការការពារស្របច្បាប់ ជាការគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់បង្ហាញភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ឡើយ។ **ឧទាហរណ៍៖** ក្នុងពេលកំពុងគេងលក់ពេលយប់ លោក **ក** បានភ្ញាក់ដឹងខ្លួន ដោយសារឮសូរសំឡេងយ៉ាងចម្លែកនៅក្នុងចង្ក្រានបាយរបស់ខ្លួន។ បន្ទាប់មក លោក **ក** ក៏ចុះទៅពិនិត្យមើលដោយកាន់កូនកាំបិតមួយនៅនឹងដៃ ហើយបានឃើញបង្អួចនៃចង្ក្រានបាយរបស់ខ្លួនមានស្នាមគាស់ទម្លុះទម្លាយ ថែមទាំងប្រទះនឹងស្រមោលរបស់មនុស្សប្រុសម្នាក់ ដែលកំពុងតែសសៀរបន្តិចម្ដងៗ សំដៅចូលមកក្នុងបន្ទប់គេងរបស់ខ្លួន។ រំពេចនោះ លោក **ក** ក៏បានចាក់ទៅលើជននោះមួយកាំបិតបណ្ដាលឱ្យស្លាប់បាត់បង់ជីវិត។ នៅក្នុងសម្មតិកម្មនេះ អំពើប្រព្រឹត្តរបស់លោក **ក** បានចាក់សម្លាប់ចោរមួយកាំបិត គឺជាបទល្មើសព្រហ្មទណ្ឌ។ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ លោក **ក** ត្រូវរកភស្តុតាងមកបញ្ជាក់អំពីលក្ខខណ្ឌនៃការការពារស្របច្បាប់។ ផ្ទុយទៅវិញ ក្នុងករណីដែលបានកើតឡើងទៅលើលោក **ក** ប្រសិនបើលោក **ក** រកភស្តុតាងមកបញ្ជាក់ថា ការសម្លាប់ចោរធ្វើឡើងដោយសារតែជននោះបានចូលមកក្នុងផ្ទះរបស់ខ្លួនក្នុងពេលយប់ ដោយ ការគាស់ទម្លុះទម្លាយ លោក **ក** មិនចាំបាច់រកភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ឡើយ ពោលគឺ ក្រមព្រហ្មទណ្ឌសន្មតថា លោក **ក** បានប្រព្រឹត្តបទល្មើសក្នុងលក្ខខណ្ឌនៃការការពារស្របច្បាប់តែម្ដង។ ថ្វីដ្បិតតែ លោក **ក** ទទួលបានផលប្រយោជន៍ពីសច្ចធារណ៍នៃការការពារស្របច្បាប់ក៏ពិតមែន ប៉ុន្តែតំណាងអយ្យការអាចរកភស្តុតាងផ្ទុយមករំលាយសច្ចធារណ៍នេះបាន ដោយលើកឡើងពីចំណុចខ្វះខាតលក្ខខណ្ឌនៃការការពារស្របច្បាប់ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[50] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៤។

**ស្ថានភាពចាំបាច់៖** ស្ថានភាពរបស់បុគ្គលម្នាក់ដែលស្ថិតនៅក្នុងការចាំបាច់ ត្រូវតែប្រព្រឹត្តបទល្មើស ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងទៅនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន ដោយប្រើប្រាស់មធ្យោបាយការពារសមាមាត្រទៅនឹងទម្ងន់នៃគ្រោះថ្នាក់។[51] សម្រាប់ស្ថានភាពចាំបាច់ ជនដែលប្រព្រឹត្តបទល្មើស បានជ្រើសរើសយកការប្រព្រឹត្តបទល្មើស ដោយសារតែបុគ្គលនោះមានបំណងចង់ជួយស្តារនូវផលប្រយោជន៍ណាមួយ ដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងតែកើតមាន ឬដែលនឹងកើតមាន។ **ឧទាហរណ៍៖** ដើម្បីជួយសង្គ្រោះជនរងគ្រោះដោយសារអគ្គិភ័យ បុរសម្នាក់បានធាក់ទ្វារផ្ទះរបស់អ្នកជិតខាងឱ្យរបើក ព្រមទាំងបានវាយបំបែកបង្អួចផ្ទះ ដើម្បីអាចចូលទៅក្នុងផ្ទះរបស់ជនរងគ្រោះ។ ករណីនេះ គឺជាស្ថានភាពចាំបាច់ ហេតុដូច្នេះ បុរសម្នាក់នោះអាចរួចផុតពីការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ដោយសារតែស្ថានភាពចាំបាច់ ត្រូវការធាក់ទ្វារផ្ទះ និងការវាយបំបែកបង្អួចផ្ទះរបស់អ្នកដទៃ។

**អ្នកប្រព្រឹត្តជាអនីតិជន៖** នីតិភាពនៃការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។[52] ជនល្មើស មានអាយុចាប់ពី ១៨ (ដប់ប្រាំបី )ឆ្នាំ ឡើងទៅ ទើបតុលាការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបាន ដោយទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[53] ក៏ប៉ុន្តែ អនីតិជនមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ឡើងទៅ តុលាការអាចវិនិច្ឆ័យទោសទៅតាមកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះបាន។[54] នៅក្នុងករណី ដែលចៅក្រមសម្រេចចោទប្រកាន់ អនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ បានកំណត់ថាមូលទោស ដែលត្រូវចោទប្រកាន់ទៅលើបទល្មើសដែលបានប្រព្រឹត្តនោះត្រូវបានបន្ថយក្នុងលក្ខខណ្ឌ អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ឬអប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាលប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។ ប្រសិនបើ អតិបរមានៃទោសនោះជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។[55] ដោយឡែក ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន និងប្រគល់អនីតិជនឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ នៅក្នុងករណីដែលអនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃសង្ស័យចូលរួមប្រព្រឹត្តបទល្មើស។[56]

[51] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៥។
[52] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៨។
[53] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤៣។
[54] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៣៩។
[55] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា១៦០។
[56] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦, មាត្រា២៧ កថាខណ្ឌ១។

### ២.២.២.៣. បទល្មើសដែលមានព្យសនកម្មតិចតួច

តំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ក្រោយពីបង្គាប់ឱ្យធ្វើការស្រាវជ្រាវ អំពីស្ថានការណ៍ដែលបណ្តាលឱ្យមានបទល្មើសកើតឡើង កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស មិនបានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គមសាធារណៈ ទោះបីជាមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបង្ហាញថាជា បទល្មើសព្រហ្មទណ្ឌក៏ដោយ ប្រសិនបើតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនល្មើសនោះក៏មិនទទួលបានផលប្រយោជន៍ដល់សង្គមជាតិដែរ។ **ឧទាហរណ៍៖** ស្ត្រីមានផ្ទៃពោះម្នាក់ បានទៅលួចបេះផ្លែស្វាយអ្នកជិតខាងដើម្បីយកមកបរិភោគ ដោយសារតែគាត់ជាស្ត្រីមានផ្ទៃពោះ ហើយក្រីក្រគ្មានប្រាក់ក្នុងការទិញស្វាយយកមកបរិភោគ ខ្វះខាតជីវភាពក្នុងការចិញ្ចឹមជីវិតផង។ តាមរយៈការសិក្សាលើ អង្គហេតុនេះ ស្ត្រីមានផ្ទៃពោះបានប្រព្រឹត្តបទល្មើសលួច យោងតាមមាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានថ្លែងអំពីរយៈអំពើលួចនឹងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌដែល ចែងអំពីទោស។ ការប្រព្រឹត្តបទល្មើសនេះមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ប៉ុន្តែប្រសិនបើមើលទៅលើមូលហេតុ និងផលប្រយោជន៍ ដែលជននោះទទួលបានពីការប្រព្រឹត្តបទល្មើសវិញគឺ មានព្យសនកម្មតិចតួច និងដោយសារតែកត្តាជីវភាពរបស់ជននោះរួមជាមួយភាពស្រេកឃ្លានដើម្បីបានបរិភោគ។ ហេតុនេះហើយតំណាងអយ្យការ អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ទោះបីជាធ្វើការចោទប្រកាន់ក៏មិនបានទទួលបានផលប្រយោជន៍អ្វីឡើយ។

### ២.២.២.៤. ការមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើស

ការមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើស ក៏ជាមូលហេតុដែលបណ្តាលឱ្យតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការបានដែរ នៅពេលដែលអត្តសញ្ញាណរបស់ជនល្មើសនោះមិនអាចកំណត់បានដោយគ្មានសាវតាជាតិរបស់ជនល្មើស នៅក្នុងករណីបទល្មើសមួយដែលបានកើតឡើង។ តំណាងអយ្យការអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្រោយពីបានទទួលបានការស៊ើបអង្កេតបឋម ឬធ្វើការស្រាវជ្រាវបន្ថែមដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតនៅក្រោមការដឹកនាំនឹងសម្របសម្រួលរបស់ព្រះរាជអាជ្ញា។[57] បន្ទាប់ពីធ្វើការស៊ើបអង្កេតហើយមិនអាចកំណត់ពីអត្តសញ្ញាណរបស់ជនល្មើសបាន ជាហេតុមិនអាចបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះដោយផ្ទាល់នឹងនាំឱ្យខាតបង់ផលប្រយោជន៍ផងនោះព្រះរាជអាជ្ញាអាចសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។ **ឧទាហរណ៍៖** អំពើហិង្សាមួយកើតឡើងអំឡុងពេលកំពុងរាំផុងបាសពេលយប់ក្នុងភូមិមួយ។ នៅពេលនោះ មន្ត្រីនគរបាលយុត្តិធម៌បានចុះមកធ្វើការស៊ើបអង្កេត ក្រោយពីបានសាកសួរនៅក្នុងកន្លែងកើតហេតុជនបង្ក គឺមិនមែនអ្នកក្នុងភូមិនោះទេ។ ដោយសារតែ

[57] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤០ កថាខណ្ឌ២។

ពេលកើតហេតុជាពេលយប់ ទើបបានជាមិនមានអ្នកណាស្គាល់ពីជនសង្ស័យ ព្រមទាំងព័ត៌មានផ្ទាល់ខ្លួនថាមកពីណា ហើយស្នាក់នៅកន្លែងណា គឺមិនមានតម្រុយអ្វីទាក់ទងនឹងជនសង្ស័យនោះឡើយ។ នៅក្នុងករណីនេះ ប្រសិនជាមន្ត្រីនគរបាលយុត្តិធម៌មិនអាចកំណត់អំពីអត្តសញ្ញាណរបស់ជនល្មើសនោះបាន ព្រះរាជអាជ្ញាអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបានស្របទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

## ២.៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ២.៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

មុននឹងសម្រេចចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យស្រាវជ្រាវបន្ថែម។ បន្ទាប់មក គឺការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយបានស្រាវជ្រាវបានចប់សព្វគ្រប់ហើយ យល់ឃើញថាត្រូវតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការនឹងធ្វើការសម្រេចដោយចេញដីកាមួយឈ្មោះថា ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ទៀតសោត តំណាងអយ្យការត្រូវជូនដំណឹងទៅអ្នកប្តឹងអំពីសេចក្តីសម្រេចឱ្យបានឆាប់បំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលពាក្យប្តឹងចុះក្នុងបញ្ជីដែលមានចែងក្នុងមាត្រា៥០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។[58] ការជូនដំណឹងនេះជាលក្ខខណ្ឌចាំបាច់សម្រាប់ឱ្យអ្នកប្តឹងអាចតវ៉ា ចំពោះការមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ។

### ២.៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ។ នៅពេលមានការតម្កល់រឿងទុកឥតចាត់ការ គឺពុំបានបង្កើតអានុភាពអាជ្ញាអស់ជំនុំទេ។[59] នៅក្នុងករណី ដែលព្រះរាជអាជ្ញាស្វែងរក ឬទទួលនូវភស្តុតាងថ្មីសម្រាប់ធ្វើការដាក់បន្ទុក ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់សារជាថ្មីម្តងទៀតបាន លើកលែងតែបណ្តឹងអាជ្ញាត្រូវរលត់។ ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការពុំបានបង្កើតអាជ្ញាអស់ជំនុំទេ នោះមានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់ឡើងវិញនៅពេលក្រោយបាន ទោះបីបានធ្វើការតម្កល់រឿងទុកឥតចាត់ការរួចហើយក៏ដោយ។

## ២.៤. នីតិវិធីនៃការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ

នីតិវិធីនៃការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ គឺជានីតិវិធីដែលធ្វើឡើង ក្នុងគោលបំណងនាំឱ្យមានការចោទប្រកាន់ធ្វើឡើងសារជាថ្មី នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ។

---

[58] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ១។

[59] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ២។

### ២.៤.១. ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ

ការតម្កល់រឿងទុកឥតចាត់ការ គឺពុំអាចបង្កើតអានុភាពអាជ្ញាអស់ជំនុំនោះទេ មិនតែប៉ុណ្ណោះតំណាងអយ្យការអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន ប្រសិនបើបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ។[60] មូលហេតុដែលច្បាប់បានអនុញ្ញាតឱ្យព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់ឡើងវិញបាន ដោយហេតុថាការសម្រេចតម្កល់រឿងទុកឥតចាត់ការអាចនឹងមានភាពខុសឆ្គង ឬមានភាពខ្វះចន្លោះនៅក្នុងប្រការណាមួយ ដែលនាំឱ្យមានការសម្រេចសេចក្តីមានភាពមិនត្រឹមត្រូវទៅតាមនីតិច្បាប់។ កាលដែល ព្រះរាជអាជ្ញាសម្រេចចោទប្រកាន់សារជាថ្មីបាន អាចដោយហេតុថាមានអង្គហេតុថ្មីដែលត្រូវបានរកឃើញ ឬមានភស្តុតាងណាមួយបានលេចឡើង ហើយបង្កើតឱ្យអំពើល្មើសនោះក្លាយទៅជាបទល្មើសព្រហ្មទណ្ឌពេញលេញ ដែលអាចនាំឱ្យធ្វើការចោទប្រកាន់បាន។ ដូចនេះ ការបើកផ្លូវឱ្យព្រះរាជអាជ្ញាអាចធ្វើការសើរើកែប្រែសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនឡើងវិញ គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញា បានការពារផលប្រយោជន៍របស់ជនរងគ្រោះ និងមិនអនុញ្ញាតឱ្យជនល្មើសរួចផុតពីការចោទប្រកាន់នូវអំពើល្មើសដែលខ្លួនបានប្រព្រឹត្តនោះទេ។

### ២.៤.២. ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

នៅក្នុងករណីដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានសម្រេចតម្កល់រឿងទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។[61] ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ាធ្វើឡើងតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ។ បន្ទាប់មកសំណុំរឿងត្រូវបញ្ជូនភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង។ ប្រសិនបើយល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដាក់បញ្ចូលក្នុងសំណុំរឿង ហើយបញ្ជូនមកឱ្យព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់វិញ។ ប៉ុន្តែប្រសិនបើ ការតវ៉ាមិនមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់ព្រះរាជាអាជ្ញាអមសាលាដំបូងទុកជាបានការ រួចត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ដល់អ្នកប្តឹងតវ៉ា។[62]

[60] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ៣។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៦។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ៤, ៥ និង៦។

### ២.៤.៣. ការធ្វើអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹងអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋាន យ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។ ទៀតសោត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។ ចំពោះព្រះរាជអាជ្ញាមានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។[63]

ដោយឡែក ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម។ ប៉ុន្តែនៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួន ដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[64]

### ២.៤.៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រុមស៊ើបសួរ។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញា នៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[65] បន្ទាប់មក ចៅក្រមស៊ើបសួរនឹងបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញាដើម្បីឱ្យធ្វើការចោទប្រកាន់។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៩។
[64] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣០។
[65] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥។

# ជំពូកទី៣
# ការចោទប្រកាន់របស់អង្គការអយ្យការអមសាលាដំបូង

នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដំណាក់ការចោទប្រកាន់ គឺជាដំណាក់កាលមួយដែលអនុវត្តដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា គឺជាម្ចាស់បណ្តឹងអាជ្ញានៅក្នុងការធ្វើបណ្តឹង និងចោទប្រកាន់ជនល្មើស។ លើសពីនេះទៅទៀត ការចោទប្រកាន់ត្រូវបានធ្វើឡើង បន្ទាប់ពីព្រះរាជអាជ្ញាទទួលបាននូវពាក្យប្តឹង និងពាក្យបរិហារដែលទាក់ទងទៅនឹងរឿងក្តីដែលជាបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយត្រូវបានទទួលដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ព្រមទាំងបុគ្គលដទៃផ្សេងទៀតក្រៅពីជនរងគ្រោះ ឬដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបញ្ជូនមកព្រះរាជអាជ្ញា។ នៅក្នុងនោះព្រះរាជអាជ្ញា ដែលជាម្ចាស់បណ្តឹងអាជ្ញាតែងតែប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួនក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍ទូទៅ ដូចនេះព្រះរាជអាជ្ញាមិនអាចបដិសេធសំណុំរឿងណាមួយ ដោយមិនធ្វើការចោទប្រកាន់នោះទេ ប្រសិនបើសំណុំរឿងនោះមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់ ហើយត្រូវបានរកឃើញថាមានអត្ថិភាពនៃបទល្មើស និងជនល្មើសមានពិរុទ្ធភាព ហើយមានស្ថានភាពចាំបាច់ដើម្បីសម្រេចធ្វើការចោទប្រកាន់។

តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមនីតិវិធី ៣ យ៉ាងគឺ៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការចោទប្រកាន់តាមរយៈការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

## ៣.១. ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ

ដើម្បីឱ្យចៅក្រមស៊ើបសួរមានសមត្ថកិច្ចបើកការស៊ើបសួរបាន លុះត្រាតែព្រះរាជអាជ្ញាធ្វើការបញ្ជូនរឿងក្តីតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ដីកាផ្តើមចោទប្រកាន់របស់ព្រះរាជអាជ្ញា) ព្រោះចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។[66] នៅក្នុងការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺមានភាពខុសគ្នាពីការស្រាវជ្រាវដែលបានធ្វើឡើងដោយព្រះរាជអាជ្ញា ដោយហេតុថា ព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវទៅលើព័ត៌មាន និងភស្តុតាងទាំងឡាយណាដើម្បីបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌនៅក្នុងការចោទប្រកាន់។ ទៀតសោត សំណុំរឿងដែលត្រូវបានបញ្ជូនឱ្យចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយធ្វើការស៊ើបសួរនោះចៅក្រមស៊ើបសួរត្រូវតែបំពេញកិច្ចរបស់ខ្លួន ហើយធ្វើការស្រាវជ្រាវដើម្បីស្វែងរកឱ្យឃើញពីអត្ថិភាព ឬនត្ថិភាពនៃ

[66] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៤ កថាខណ្ឌ៣។

បទល្មើស ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ ហើយចៅក្រមស៊ើបសួរនឹងត្រូវធ្វើការស្រាវជ្រាវនូវរាល់គ្រប់ទិន្នន័យ នៃព័ត៌មានទាំងអស់ដែលរួមមាន៖ ភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។[67]

### ៣.១.១. លក្ខខណ្ឌនាំឱ្យមានការស៊ើបសួរ

ជាទូទៅមិនមែនគ្រប់បទល្មើសទាំងអស់ត្រូវតែធ្វើការបើកការស៊ើបសួរនោះឡើយ ហើយក៏មិនមែនមានន័យថាគ្រប់បទល្មើសទាំងអស់នោះ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរនោះដែរ នៅក្នុងការសម្រេចពីបញ្ហានេះគឺព្រះរាជអាជ្ញាត្រូវតែគោរពតាមលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិទុក។ ចំពោះប្រភេទនៃបទល្មើស ដែលអាចធ្វើការស៊ើបសួរបានមាន ២ ប្រភេទ គឺបទឧក្រិដ្ឋ និងបទមជ្ឈិម៖[68]

**បទល្មើសឧក្រិដ្ឋ៖** នៅក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។[69] បទល្មើសឧក្រិដ្ឋ គឺជាប្រភេទបទល្មើសទាំងឡាយណាដែលមានអប្បបរមានៃទោសក្នុងការដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ និងអតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត។[70] ពីព្រោះថាកម្រិតនៃទោសទៅលើជនល្មើសមានលក្ខណៈធ្ងន់ធ្ងរ ដែលតម្រូវឱ្យមានការធ្វើការស្រាវជ្រាវយ៉ាងល្អិតល្អន់ និងជាក់លាក់ច្បាស់លាស់មុនសម្រេចនាំខ្លួនជនល្មើសធ្វើការជំនុំជម្រះនៅមុខតុលាការ ដោយសារតែចៀសវាងនៅក្នុងការជំនុំជម្រះក្តីមានការធ្វេសប្រហែស ឬមានការភាន់ច្រឡំដែលនាំឱ្យមានការប៉ះពាល់ យ៉ាងខ្លាំងដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ជនដែលត្រូវបានចោទប្រកាន់ ហើយដើម្បីធានាដល់ការអនុវត្ត ការកាត់ក្តីប្រកបដោយយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។ បទឧក្រិដ្ឋនេះ ត្រូវធ្វើការស៊ើបសួរជាមុន ដែលស្ថិតក្រោមការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយធ្វើការស៊ើបសួររួមទាំង ភស្តុតាងក្នុងការដាក់បន្ទុក និងភស្តុតាងក្នុងការដោះបន្ទុក ព្រោះដើម្បីធ្វើការត្រួតពិនិត្យដោយជាក់លាក់ និងស្វែងឱ្យការដឹងពីការពិតព្រមទាំងបង្ហាញឱ្យច្បាស់លាស់ពីការជំនុំជម្រះរបស់ប្រព័ន្ធយុត្តាធិការប្រកបដោយភាពយុត្តិធម៌។

**បទល្មើសមជ្ឈិម៖** នៅក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាក៏អាចអនុវត្តនីតិវិធីនៃការបើកការស៊ើបសួរនេះបានដែរ ដោយហេតុថាព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[71] ពីព្រោះបទល្មើសមជ្ឈិមជាប្រភេទបទល្មើសមានការដាក់ទោសឱ្យជាប់ពន្ធនាគារមានរយៈពេលលើសពី ៦ (ប្រាំមួយ)

---

[67] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៧ កថាខណ្ឌ២។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២២។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៤ កថាខណ្ឌ១។

[70] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤៦។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៥។

ថ្ងៃ និង ក្រោម ឬស្មើ និង ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[72] ការបើកការស៊ើបសួរចំពោះបទមជ្ឈិម មិនមែនជាការកំណត់ឱ្យច្បាស់អំពីប្រភេទបទមជ្ឈិមដែលមានលក្ខណៈស្មុគស្មាញយ៉ាងណានោះទេ តែស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេច ដោយធ្វើការត្រួតពិនិត្យឱ្យច្បាស់លាស់អំពីស្ថានភាពនៃបទល្មើស ប្រសិនបើជនត្រូវចោទបានប្រព្រឹត្តបទល្មើសនោះនៅតែមិនមានភស្តុតាងគ្រប់គ្រាន់ ឬមិនអាចកំណត់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទនោះបានទេ បានសេចក្តីថាសំណុំរឿងមិនទាន់មានព័ត៌មានគ្រប់គ្រាន់ ឬឯកសារមិនទាន់គ្រប់គ្រាន់ដើម្បីធ្វើការជំនុំជម្រះបាន ដូច្នេះហើយព្រះរាជអាជ្ញានឹងត្រូវធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

សរុបសេចក្តីមក បទឧក្រិដ្ឋ និងបទមជ្ឈិម ដែលធ្វើការបកស្រាយខាងលើនេះ គឺចាំបាច់ព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

### ៣.១.២. នីតិវិធីនៃការបើកការស៊ើបសួរ

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារ ដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនមក។[73] នៅក្នុងរឿងក្តីព្រហ្មទណ្ឌមុន និងព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តក្នុងការចោទប្រកាន់ ដោយនីតិវិធីបើកការស៊ើបសួរ ឬនីតិវិធីផ្សេងៗទៀត ព្រះរាជអាជ្ញាត្រូវធ្វើការវាយតម្លៃ និងធ្វើការវិនិច្ឆ័យទៅលើសំណុំរឿងតាមរយៈប្រភពនៃការបញ្ជូននីមួយៗឱ្យបានច្បាស់លាស់ជាមុនសិន។ ដោយហេតុថា ប្រភពនៃពាក្យបណ្តឹងបានមកពីពាក្យប្តឹង ដែលព្រះរាជអាជ្ញាបានទទួលដោយផ្ទាល់តាមរយៈដើមបណ្តឹង ឬតាមរយៈការបញ្ជូនសំណុំរឿងមកពីមន្ត្រីនគរបាលយុត្តិធម៌។

**ការបើកការស៊ើបសួរតាមរយៈការបញ្ជូនសំណុំរឿងដោយមន្ត្រីនគរបាលយុត្តិធម៌៖** ការបើកការស៊ើបសួរក៏ធ្វើទៅបានផងដែរ ក្រោយពីបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យបណ្តឹងបរិហារ និងពាក្យបណ្តឹងទាមទារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការបើកការស៊ើបអង្កេតបឋម ចំពោះរាល់បទល្មើសដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបាន ឬនៅពេលដែលមានបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ណាមួយបានកើតឡើង រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជាពិសេសនៅពេលមានបទល្មើសជាក់ស្តែងកើតឡើងមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការចាប់ខ្លួន ឬឃាត់ខ្លួន ទៅលើជនសង្ស័យ និងបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា។ នីតិវិធីនៃការអនុវត្តលើចំណាត់ការនៃរឿងក្តីដែលត្រូវបានបញ្ជូនមកមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម៖

---

[72] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤៧។

[73] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤០ កថាខណ្ឌ១។

- ករណីសំណុំរឿងគ្មានជនសង្ស័យ៖ សំណុំរឿងទាំងឡាយណាបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលជនសង្ស័យមិនត្រូវបានឃាត់ខ្លួន ហើយមិនបញ្ជូនមកកាន់ព្រះរាជអាជ្ញាទេ។ នៅពេលដែលព្រះរាជអាជ្ញាទទួលសំណុំរឿងនោះ ព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងអំពីអង្គហេតុដោយការត្រួតពិនិត្យមើលទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង ព្រមទាំងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកោះហៅដើមបណ្តឹង ជនសង្ស័យ សាក្សី ដើម្បីធ្វើការសាកសួរ និងស្តាប់ចម្លើយ។ ក្រោយមក នៅពេលដែលត្រួតពិនិត្យទៅឃើញថាអង្គហេតុខាងលើ គឺជាបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរព្រះរាជអាជ្ញា ត្រូវធ្វើចំណាត់ការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ និងចេញដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។
- ករណីសំណុំរឿងមានជនសង្ស័យ៖ សំណុំរឿងទាំងឡាយណាដែលត្រូវបានចាប់ជនសង្ស័យនោះបាន ឬមានការឃាត់ខ្លួនជនសង្ស័យ ដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយបាននាំខ្លួនជនសង្ស័យនោះមកអនុវត្តនីតិវិធីនៅចំពោះមុខព្រះរាជអាជ្ញា។ នៅក្រោយពេលនៃការឃាត់ខ្លួនត្រូវបានកន្លងផុតទៅនោះ ព្រះរាជអាជ្ញាអាចបើកការសាកសួរចម្លើយ និងត្រួតពិនិត្យទៅលើសំណុំរឿងរបស់ជនសង្ស័យនោះផងដែរ។ ព្រះរាជអាជ្ញាត្រួតពិនិត្យទៅលើអង្គហេតុ និងភស្តុតាង ដែលជារបាយការណ៍សំយោគនៃសំណុំរឿងដែលមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការសន្និដ្ឋាន ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ។ ករណីនេះ ប្រសិនបើការពិនិត្យលើសំណុំរឿងឃើញថាជាបទល្មើស និងបានបំពេញលក្ខខណ្ឌនៅក្នុងការបើកការស៊ើបសួរ នាំឱ្យព្រះរាជអាជ្ញានឹងចេញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ទៀតសោត ព្រះរាជអាជ្ញាអាចធ្វើការសន្និដ្ឋានសុំឱ្យចៅក្រមស៊ើបសួរដាក់ជននោះស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឱ្យជននោះស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នបានផងដែរ។

**ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងដែលបញ្ជូនមកដោយផ្ទាល់៖** ចំពោះដើមបណ្តឹងក៏អាចដាក់ពាក្យបណ្តឹងមកកាន់ព្រះរាជអាជ្ញាដោយផ្ទាល់បានផងដែរ ដើម្បីសុំឱ្យព្រះរាជអាជ្ញាធ្វើចំណាត់ការទៅលើរឿងក្តីនោះ។ នៅក្រោយពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងពីសំណាក់ដើមបណ្តឹង នោះព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងសម្រេចលើចំណាត់ការក្នុងការចោទប្រកាន់តាមរយៈនីតិវិធីណាមួយ ប្រសិនបើអង្គហេតុនៅក្នុងសំណុំរឿងនោះត្រួតពិនិត្យទៅឃើញថាជាបទល្មើស។ នីតិវិធីនៅក្នុងការថ្លឹងថ្លែង និងស្រាវជ្រាវត្រូវធ្វើឡើងតាមរយៈការសុំឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការបើកការស៊ើបអង្កេតបឋម ឬកោះហៅដើមបណ្តឹង ឬសាក្សីមកសាកសួរ និងស្តាប់ចម្លើយដោយផ្ទាល់។ បន្ទាប់ពីការស៊ើបអង្កេត និងស្រាវជ្រាវបានបញ្ចប់ ហើយបានរកឃើញថាអង្គហេតុនោះជាបទល្មើស ហើយបានបំពេញនៅលក្ខខណ្ឌដែលនាំឱ្យមានការស៊ើបសួរបានព្រះរាជអាជ្ញានឹងសម្រេចចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

### ៣.១.៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យបើកការស៊ើបសួរ

នៅពេលដែលមានការសម្រេចចោទប្រកាន់តាមរយៈការបើកការស៊ើបសួរពីព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញាចាំបាច់ត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការស៊ើបសួរ។ ចំពោះនីតិវិធីនៃការបើកការស៊ើបសួរ ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទើបកិច្ចស៊ើបសួរនេះអាចដំណើរការទៅបាន ហើយដីកានេះត្រូវធ្វើឡើងតាមប្រការមួយយ៉ាងជាក់លាក់ ដើម្បីឱ្យនីតិវិធីនេះមានអានុភាពសមស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ទៀតសោត ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យធ្វើការស៊ើបសួរនោះរួមមាន៖ **សេចក្ដីសង្ខេបនៃអង្គហេតុ ការកំណត់ឈ្មោះបទល្មើស ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចធ្វើការកំណត់បាន**។ នៅក្នុងទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះការបរិច្ឆេទ និងចុះហត្ថលេខា របស់តំណាងអយ្យការ ហើយទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ នាំឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនឹងត្រូវចាត់ទុកជាមោឃៈ។[74]

### ៣.១.៤. អានុភាពនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ

ក្រោយពីបានសម្រេចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានធ្វើឱ្យដីកានេះបង្កើតឱ្យមានអានុភាពដូចជា៖ ការផ្ដាច់រយៈពេលអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឱ្យបើកការស៊ើបសួរ និងការកំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរ មានដូចតទៅ៖

**ការកំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរ៖** នៅក្នុងកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរទទួលបណ្ដឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។ ប្រសិនបើ មានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។[75]

---

[74] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៤ កថាខណ្ឌ៣, ៤ និង៥។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៥។

**ការផ្តាច់រយៈពេលអាជ្ញាយុកាលនៃបទល្មើស៖** ចិរវេលាអាជ្ញាយុកាលនៃបទល្មើស គឺត្រូវគិតចាប់ផ្តើមពីពេលដែលបានប្រព្រឹត្តបទល្មើស។ ការចោទប្រកាន់ ឬការបើកការស៊ើបសួរបាននាំឱ្យមានការផ្តាច់អាជ្ញាយុកាល។[76] ក្នុងន័យនេះ គ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាទាំងអស់មិនថា តាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ តាមរយៈការបង្ហាញខ្លួនភ្លាម និងតាមរយៈការបើកការស៊ើបសួរនោះទេត្រូវផ្តាច់អាជ្ញាយុកាល ពីព្រោះសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។

**ការផ្ទេរសមត្ថកិច្ចទៅកាន់ចៅក្រមស៊ើបសួរដើម្បីឱ្យធ្វើការស៊ើបសួរ៖** គ្មានកិច្ចស៊ើបសួរណាមួយ អាចបើកការស៊ើបសួរបានដោយគ្មានការចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ លើកលែងតែករណីការដាក់ឱ្យមានចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរនឹងត្រូវមោឃភាព ប្រសិនបើជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការប្តឹងមោឃភាព គឺត្រូវប្តឹងទៅកាន់សភាស៊ើបសួរ គ្រប់ពេលវេលានៅពេលដែលមានការរកឃើញថាការស៊ើបសួរណាមួយខុសនីតិវិធី។ នៅពេលដែលចេញដីកាដំណោះស្រាយ គឺមានអានុភាពលុបចោលមោឃភាពនៃនីតិវិធីមុន មានន័យថា ទោះបីជាកិច្ចស៊ើបសួរណាមួយដែលអាចជាកម្មវត្ថុនៃមោឃភាពក៏ដោយ ក៏មិនអាចលើកមកពិចារណាម្តងទៀតនៅពេលជំនុំជម្រះបានដែរ។

## ៣.២. ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដើម្បីចាប់ផ្តើមនិតិវិធីក្នុងកិច្ចបញ្ជូនរឿងឱ្យជំនុំជម្រះផ្ទាល់បាន លុះត្រាតែព្រះរាជអាជ្ញាសម្រេចចេញដីកាមួយជាមុនសិន ហៅថាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។[77] ទៀតសោត ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះជានីតិវិធីមួយ ដែលអាចយកមកអនុវត្តបានចំពោះបទមជ្ឈិមតូចតាច និងគ្រប់បទលហុទាំងអស់ ហើយសំណុំរឿងនេះមានលក្ខណៈគ្រប់គ្រាន់អាចធ្វើការជំនុំជម្រះបាន។ បន្ថែមពីនេះ ដើម្បីឱ្យកិច្ចនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទារឱ្យគោរពនូវលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តឱ្យស្របទៅតាមនីតិវិធីមួយជាក់លាក់ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឱ្យនីតិវិធីនេះមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

### ៣.២.១. លក្ខខណ្ឌនាំឱ្យមានការបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដោយប្រើប្រាស់នីតិវិធីនៃការបញ្ជូនរឿងទៅឱ្យជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែចេញដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

[76] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១១។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៦ កថាខណ្ឌ១។

ដែលដីកានេះទាមទារឱ្យគោរពទៅតាមលក្ខខណ្ឌមួយចំនួន ដើម្បីធ្វើការចោទប្រកាន់បាន។ ប៉ុន្តែ ដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់លក្ខខណ្ឌច្បាស់លាស់នោះទេ គ្រាន់តែបញ្ជាក់ពីចំណុចមួយចំនួន ដែលអាចឱ្យព្រះរាជអាជ្ញាប្រើប្រាស់នៅក្នុងនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់។ លក្ខខណ្ឌនេះគឺ សំដៅទៅលើលក្ខខណ្ឌនៃបទល្មើសរបស់ជនល្មើសត្រូវបានបំពេញ និងលក្ខណៈនៃសាវតាជាតិរបស់ជនល្មើសដែលបានបំពេញ៖

**លក្ខខណ្ឌនៃបទល្មើសរបស់ជនល្មើសត្រូវបានបំពេញ៖** នៅក្នុងលក្ខខណ្ឌនៃបទល្មើសត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសព្រហ្មទណ្ឌដែលមានការបែងចែកជា ៣ ធំៗគឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានធ្វើការបកស្រាយព្រមទាំងបង្ហាញពីជាតុផ្សំនៃបទល្មើស បទលហុ និងបទមជ្ឈិម ដែលបានផ្តល់អំណាចឱ្យព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ដោយប្រើប្រាស់នីតិវិធីបញ្ជូនរឿងឱ្យជំនុំជម្រះផ្ទាល់។ បទល្មើសដែលបានកើតឡើង ហើយច្បាប់ទទួលស្គាល់ថាជាបទល្មើស លុះត្រាតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់ច្បាស់ថាជាបទល្មើស និងច្បាប់បានកំណត់ថាជាទោស។ ដូច្នេះហើយការបញ្ជូនទៅជំនុំជម្រះផ្ទាល់មិនសូវស្មុគស្មាញ និងមានភស្តុតាងគ្រប់គ្រាន់ដែលអាចជំនុំជម្រះបាន ហើយអាចធ្វើបានចំពោះបទមជ្ឈិម និងបទលហុ តែប៉ុណ្ណោះ ដែលជាកត្តាមួយជួយជម្រុញដល់ការពន្លឿននីតិវិធីតុលាការឱ្យបានឆាប់រហ័ស មិនអូសបន្លាយពេលវេលា និងជាពិសេសការពារផលប្រយោជន៍ជនល្មើស និងជនរងគ្រោះ។

- ចំពោះបទល្មើសលហុ៖ បទល្មើសលហុ គឺសំដៅទៅលើបទល្មើសទាំងឡាយណា ដែលត្រូវបានទទួលទោសដាក់ពន្ធនាគាររយៈពេលអតិបរមានៃទោស ស្មើ ឬមិនលើសពី ៦ (ប្រាំមួយ) ថ្ងៃ ឬទោសពិន័យជាប្រាក់តែប៉ុណ្ណោះ។[78] នៅពេលមានអង្គហេតុកើតឡើងដែលមានស្ថានភាពជាបទល្មើសលហុនោះនាំឱ្យព្រះរាជអាជ្ញានឹងសម្រេចចេញដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់តែម្តង ដោយសារតែប្រភេទនៃបទល្មើសនេះមានលក្ខណៈនៅក្នុងការផ្តន្ទាទោសស្រាលតែប៉ុណ្ណោះ។[79] ផ្ទុយទៅវិញ ប្រសិនបើជននោះត្រូវរងការចោទប្រកាន់ ដោយប្រើនីតិវិធីផ្សេងៗដូចជា ការចូលបង្ហាញខ្លួនភ្លាម ឬការបើកការស៊ើបសួរ នាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងរដល់ជនជាប់ចោទ ពីព្រោះតាមនីតិវិធីចូលបង្ហាញខ្លួន និងនីតិវិធីនៃការបើកការស៊ើបសួរ ទាមទារឱ្យមានការឃុំខ្លួនជនជាប់ចោទរហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

---

[78] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, មាត្រា៤៨។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៩។

- ចំពោះបទល្មើសមជ្ឈិមៈ បទល្មើសមជ្ឈិម គឺជាប្រភេទបទល្មើសមានការដាក់ទោសឱ្យជាប់ពន្ធនាគារ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើ និង ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវបន្ថែមនូវទោស ពិន័យជាប្រាក់ផងដែរ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ពុំបានធ្វើការបញ្ជាក់ច្បាស់ ពីប្រភេទបទល្មើសមជ្ឈិមបែបណា ដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការជំនុំជម្រះផ្ទាល់បាន ទោះបីជា បទល្មើសជាក់ស្តែង ឬមិនជាក់ស្តែងក៏ដោយ ព្រោះច្បាប់បានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាជាអ្នក ថ្លឹងថ្លែងនៅក្នុងការសម្រេចលើស្ថានភាពនៃអង្គហេតុបទល្មើស។ នៅក្នុងករណី ដែលព្រះរាជអាជ្ញាបាន ត្រួតពិនិត្យឃើញមានភស្តុតាងគ្រប់គ្រាន់ នាំឱ្យតុលាការនឹងជំនុំជម្រះសម្រេចសេចក្តីទៅលើបទល្មើស នោះបាន ដោយព្រះរាជអាជ្ញានឹងប្រើប្រាស់នីតិវិធីចោទប្រកាន់នេះ។ យ៉ាងណាមិញ បទល្មើសមជ្ឈិម អាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទម្រង់នៃការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឱ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀត បាន។ ក្នុងនោះ ឃើញថាស្ថានភាពនៃបទល្មើសមជ្ឈិមខ្លះអាចមានករណីមួយចំនួន ដែលមានលក្ខណៈ ស្មុគស្មាញ ឬស្ថានភាពដោយឡែកផ្សេងទៀតតម្រូវទាមទារឱ្យមានការបើកការស៊ើបអង្កេត កាលណា មិនទាន់មានភស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម។

**លក្ខខណ្ឌនៃសាវតារបស់ជនល្មើសត្រូវបានបំពេញ៖** បន្ទាប់ពីការកំណត់ប្រភេទនៃបទល្មើសចប់សព្វ គ្រប់ ហើយកត្តាចម្បងនោះ គឺព្រះរាជអាជ្ញាចាំបាច់ត្រូវរកឱ្យឃើញពីសាវតាជាតិរបស់ជនល្មើសនោះ ព្រោះជា មូលហេតុចាំបាច់សម្រាប់ធ្វើការកំណត់បង្ហាញពីលក្ខខណ្ឌមួយក្នុងការធ្វើបណ្តឹងអាជ្ញា ហើយដែលមានគោល បំណង ក្នុងការស្វែងរកអត្ថិភាពនៃបទល្មើស បូករួមទាំងការផ្តន្ទាទោសទៅលើជនល្មើសផងដែរ។ នីតិវិធីនៃការ បញ្ជូនរឿងឱ្យជំនុំជម្រះផ្ទាល់នេះ ចាំបាច់ត្រូវធ្វើការទាមទារកំណត់អំពីអត្តសញ្ញាណរបស់ជនល្មើស ដោយខាន មិនបាន ប្រសិនបើជនល្មើសមិនបានស្ថិតក្នុងភាពស្គាល់អត្តសញ្ញាណនោះទេ នាំឱ្យដីកាបញ្ជូនរឿងជំនុំជម្រះ ផ្ទាល់មិនអាចប្រព្រឹត្តបានទេ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានធ្វើការទទួលស្គាល់វិសាលភាពនៃ បណ្តឹងចំពោះជនជាប់ចោទ បានសេចក្តីថាតុលាការនឹងធ្វើការជំនុំជម្រះទៅលើជនទាំងឡាយណាដែលមានក្នុង ពាក្យបណ្តឹងតែប៉ុណ្ណោះ។ ដូច្នេះ ការស្គាល់នូវអត្តសញ្ញាណរបស់ជនល្មើសគឺជាកត្តាចាំបាច់ និងជាលក្ខខណ្ឌ ដែលមិនអាចខ្វះបានឡើយ។

### ៣.២.២. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីការបញ្ជូនរឿងជំនុំជម្រះផ្ទាល់ សំដៅទៅលើនីតិវិធីមួយដែលមិនចាំបាច់ធ្វើការឆ្លងកាត់នូវដំណាក់ កាលស៊ើបសួរនោះទេ ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ភ្លាមតាមរយៈពាក្យបណ្តឹង និងលក្ខ ខណ្ឌនៃការបញ្ជូនរឿងជំនុំជម្រះផ្ទាល់ បន្ទាប់មកក៏បញ្ជូនសំណុំរឿងនេះតាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់

ទៅកាន់យុត្តាធិការជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះផ្ទាល់ និងចេញដីកាកោះហៅជនជាប់ចោទចូលមកសវនាការធ្វើការជំនុំជម្រះ។ ដោយដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាលិខិតដែលព្រះរាជអាជ្ញាអាចបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅតុលាការជំនុំជម្រះ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់នេះ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌឱ្យស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលបានបង្ហាញក្នុងគោលបំណងធានាឱ្យដីកាកោះហៅមានសុពលភាព។ ដូចបានរៀបរាប់ខាងលើ លក្ខខណ្ឌត្រូវបានបំពេញគ្រប់គ្រាន់ហើយបទល្មើសដែលត្រូវចោទប្រកាន់គឺជាបទលហុ ដោយមិនទាមទារឱ្យមានការស៊ើបអង្កេតបន្ថែម ព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួននៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ហើយមិនអាចជ្រើសរើសវិធីចោទប្រកាន់ផ្សេងនោះទេ។[80] នៅក្នុងករណី លក្ខខណ្ឌនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មិនបានបំពេញ ដូចជាជនល្មើសមិនត្រូវបានគេស្គាល់ ឬទាមទារឱ្យស្រាវជ្រាវបន្ថែមទៀតនោះ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ប៉ុន្តែចំពោះករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការជ្រើសរើសយកការបើកការស៊ើបសួរ ឬបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង ឬបង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង។[81]

ដោយឡែកដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវប្រគល់ឱ្យជនជាប់ចោទនៅក្នុងចិរវេលានៃការកោះហៅមួយដែលកំណត់ដោយច្បាប់ និងស្របតាមរបៀបបែបបទនៃការប្រគល់មួយច្បាស់លាស់ ជៀសវាងការបង្កើតឱ្យមានមោឃភាពនៃនីតិវិធី។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីអមខ្លួនបាន។

**ចិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖** រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញនៅមុខតុលាការត្រូវកំណត់ដូចតទៅ៖ ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង ចំនួន ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ ចំនួន ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា ចំនួន ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។[82]

**របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖** ការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃ ដោយព្រះរាជអាជ្ញា។ នៅក្នុងករណីនេះ

---

[80] រៀបរៀងដោយលោក ចក សម្បត្តិ, ការចោទប្រកាន់បីរបៀបរបស់ព្រះរាជអាជ្ញា, ព្រឹត្តិបត្រច្បាប់សាលាត្រាជូ, លេខទី៤ ខែមករា ឆ្នាំ២០២៣, ទំព័រ៩៨។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៥។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៥៧។

ព្រះរាជអាជ្ញាបញ្ជូនដីកាកោះទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ។ ព្រះរាជអាជ្ញា ចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងកន្លែងប្រគល់ដីកា នៅលើដីកាដើម។ ជនជាប់ចោទចុះហត្ថលេខានៅលើដីកាដើមនេះ។ ចំពោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ដោយអាជ្ញាសាលាបានដែរ។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឱ្យជនជាប់ចោទដោយផ្ទាល់ដៃ។[83] របៀបផ្សេងទៀត នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចធ្វើឡើងតាមរយៈក្រឡាបញ្ជីតាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា។[84]

### ៣.២.៣. ទម្រង់នៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់

ព្រះរាជអាជ្ញានឹងអនុវត្តដីកាកោះហៅបញ្ជូនមកទៅជំនុំជម្រះផ្ទាល់ឡើង ដោយមានទម្រង់ច្បាស់លាស់ និងជាក់លាក់ ដើម្បីងាយស្រួលដល់ចៅក្រមជំនុំជម្រះត្រួតពិនិត្យ និងវិនិច្ឆ័យថាបទល្មើស ដែលចៅក្រមធ្វើការចោទប្រកាន់នោះត្រឹមត្រូវតាមនីតិវិធីច្បាប់។ ទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់ ដែលជាមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងកំណត់នូវផលប្រយោជន៍ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះ ហើយទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន៖ **អត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស**។[85]

**អត្តសញ្ញាណនៃជនជាប់ចោទ៖** ការកំណត់អំពីអត្តសញ្ញាណជនជាប់ចោទ គឺមានសារប្រយោជន៍ដល់កិច្ចជំនុំជម្រះគ្រង់ដែននៃការប្តឹងចំពោះបុគ្គល និងមានន័យគ្រប់គ្រាន់ថាជាបណ្តឹងចោទប្រកាន់ចំពោះជនល្មើស ព្រោះប្រសិនបើគ្មានការកំណត់អត្តសញ្ញាណនៃជនជាប់ចោទទេ មានន័យថាគ្មានការចោទប្រកាន់លើបទព្រហ្មទណ្ឌកើតមានឡើងនោះទេ។

**សេចក្តីសង្ខេបនៃអង្គហេតុ៖** ការកំណត់ពីសេចក្តីសង្ខេបអង្គហេតុ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះគ្រង់ដែននៃការប្តឹងចំពោះអង្គហេតុ និងនាំឱ្យដឹងថាបណ្តឹងនោះប្តឹងអំពីអ្វី ព្រោះមិនកំណត់អង្គហេតុ ដែលព្រះរាជអាជ្ញាមិនបានចោទប្រកាន់លើអង្គហេតុនោះទេ ជាហេតុនាំឱ្យគ្មានបណ្តឹង។

**ឈ្មោះបទល្មើស៖** សំដៅដល់បទល្មើសដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ។

---

[83] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៥៩។
[84] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៦៣។
[85] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៦។

**អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** សំដៅទៅលើបទល្មើស ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយត្រូវពឹងផ្អែកទៅលើបទប្បញ្ញត្តិនៃច្បាប់។

សរុបសេចក្តីមក ក្រៅពីទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់ខាងលើ ព្រះរាជអាជ្ញាក៏ត្រូវចង្អុលប្រាប់ដល់ជនជាប់ចោទពីតុលាការ ព្រមទាំងទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការផងដែរ ព្រោះការជូនដំណឹងនេះមានភាពងាយស្រួល ដោយមិនចាំបាច់ចេញដីកាកោះហៅឱ្យចូលសវនាការទេ ដោយហេតុថា ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ បានបញ្ជាក់ប្រាប់ដល់ជនជាប់ចោទរួចអស់ហើយ។ ទៀតសោត នៅដើមដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅឋានរបស់ជនជាប់ចោទ ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។[86]

### ៣.២.៤. អានុភាពនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ នាំឱ្យមានការបង្កើតនូវអានុភាពមួយចំនួនមាន ជាអាទិ៍ ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ។

**ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជានីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលជាហេតុនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ ប្រសិនបើគ្មានការកំណត់បែបនេះទេ អាចមានករណីខ្លះនៅពេលដែលបណ្តឹងបញ្ជូនទៅតុលាការ តែត្រូវផុតអាជ្ញាយុកាលដែលនាំឱ្យជនល្មើសត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនទៅវិញ។

**ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** ករណីនេះខុសពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរឱ្យបើកកិច្ចស៊ើបសួរ តែដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវបានប្រគល់សំណុំរឿងទៅតុលាការធ្វើការជំនុំជម្រះតែម្តង ដោយមិនចាំបាច់ឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរឡើយ។

**ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ៖** តុលាការអាចសម្រេចសេចក្តីបានតែទៅលើអង្គហេតុទាំងឡាយណា ដែលមានបង្ហាញនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ នៅក្នុងករណីតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទមជ្ឈិម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល។ ក្នុងករណី ដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។[87] ទៀតសោត តុលាការអាចជំនុំជម្រះបុគ្គល

[86] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៥៦។

[87] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៤៨។

ដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាដែលកោះហៅឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជា ជនដៃដល់ ឬអ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបានក្រោយពីត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ការចោទប្រកាន់) តែប៉ុណ្ណោះ។[88]

## ៣.៣. ការចោទប្រកាន់តាមរយៈការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ជានីតិវិធីមួយក្នុងចំណោមនីតិវិធីទាំងបីនៃការចោទប្រកាន់ ខាងបទល្មើសព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា ដែលអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង។ នីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមនេះ ជានីតិវិធីឆាប់រហ័សមួយសម្រាប់ធ្វើឡើងយ៉ាងណាឱ្យបានចំណេញពេលវេលា និងជាពិសេសការពារផលប្រយោជន៍ជនល្មើស និងជនរងគ្រោះ ហើយជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាជួយសម្រួលដល់វិស័យយុត្តិធម៌ក្នុងតុលាការកម្ពុជាផងដែរ។ នីតិវិធីបង្ហាញខ្លួនភ្លាមនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅស្របតាមនីតិវិធី និងឈានទៅដល់ការបង្កើតឱ្យមានអានុភាពមួយចំនួន។

### ៣.៣.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ប្រសិនបើមានលក្ខខណ្ឌដូចតទៅ៖[89]

**បទល្មើសជាបទមជ្ឈិមជាក់ស្តែង៖** បទល្មើសជាបទមជ្ឈិមជាក់ស្តែង តាមអត្ថន័យនៃមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ៖** គឺជាការបង្ហាញឱ្យឃើញកាន់តែច្បាស់ថា បទល្មើសត្រូវតែជាបទមជ្ឈិម ដែលការផ្តន្ទាទោសអតិបរមានៃកម្រិតទោសនីមួយៗ ១ (មួយ) ឆ្នាំ និងអតិបរមានៃកម្រិតទោសនីមួយៗ ៥ (ប្រាំ) ឆ្នាំ។

**ជនជាប់ចោទជានីតិជន៖** មានន័យថាការដែលជនជាប់ចោទត្រូវដល់នីតិភាព ដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ការកំណត់បែបនេះ ដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិរបស់អនីតិជន ដោយ

---

[88] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣៥៩។

[89] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៧។

ហេតុថានីតិវិធីនេះមានការជំនុំជម្រះលឿន ហើយបើមិនបានកំណត់ជនជាប់ចោទជានីតិជនទេ នាំឱ្យមានការប៉ះពាល់ទៅដល់សិទ្ធិការពារខ្លួនរបស់អនីតិជននោះ។

**រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖** ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាងគ្រប់គ្រាន់ នៅក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ ព្រោះបើគ្មានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកជនល្មើសនោះទេ នាំឱ្យតុលាការសម្រេចឱ្យជននោះរួចខ្លួន ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ជាថ្មីបាន ដោយសារគោលការណ៍អាជ្ញាអស់ជំនុំ។

### ៣.៣.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលមានលក្ខណៈខុសប្លែកពីនីតិវិធីទាំងពីរខាងលើ ដោយហេតុថា នីតិវិធីនេះមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាមចែកចេញជា ២ ដំណាក់កាលគឺ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា និងនីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ៖

**នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា៖**[90] បន្ទាប់ពីបានពិនិត្យមើលទៅលើអង្គហេតុ ដែលជាពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ប្រសិនបើត្រូវជ្រើសរើសនីតិវិធីនៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមនោះព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលត្រូវបញ្ជូនមកឱ្យខ្លួន៖ ការធ្វើបែបនេះ ដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វីដែលកំណត់ហេតុបានកត់ត្រា ឬទេ។
- ឱ្យដំណឹងដល់ជននោះ អំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស៖ ការទទួលយកបែបនេះព្រោះ ជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងឮអំពីមូលហេតុអ្វីដែលគេចោទមកខ្លួន នេះជាស្មារតីលើការទទួលស្គាល់លើសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ៖ ចំណុចនេះក៏ជាសិទ្ធិសេរីភាពរបស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាង ដោយធ្វើការលើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹងជាផលប្រយោជន៍របស់ខ្លួន។
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម៖ ដើម្បីជាការចោទប្រកាន់ទៅតុលាការ ព្រះរាជអាជ្ញាត្រូវចេញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម រួចបញ្ជូនទៅតុលាការជាន់ដំបូង ដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការបើកសវនាការ។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៨។

ដោយឡែក នៅក្នុងកំណត់ហេតុនេះចាំបាច់ត្រូវតែមានការចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិ នៅក្នុងការពឹងពាក់មេធាវីដែលអាចជ្រើសរើស ដោយខ្លួនឯង ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ ក្នុងករណីនេះ មេធាវីត្រូវទទួលដំណឹងភ្លាមដើម្បីទទួលស្គាល់នូវសិទ្ធិមានរយៈពេលគ្រប់គ្រាន់ ដើម្បីការពារខ្លួនរបស់ជនជាប់ចោទ។ និទ្ទេសនៃទម្រង់ការខាងលើ ត្រូវតែចុះក្នុងកំណត់ហេតុ បើមិនដូច្នោះទេត្រូវចាត់ទុកថាមោឃៈ។ ក្រោយពីធ្វើកំណត់ហេតុរួចហើយ ជនជាប់ចោទត្រូវបង្ខាំងទុកដោយកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។

**នីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ៖**[91] នៅពេលដែលទទួលបានកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាម តុលាការត្រូវធ្វើការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទឱ្យបានច្បាស់លាស់ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុដែលព្រះរាជអាជ្ញាបានចោទប្រកាន់នោះ ហើយត្រូវប្រាប់ដល់ជនជាប់ចោទពីរយៈពេលសម្រាប់រៀបចំដើម្បីការពារខ្លួន។ ប្រសិនបើ ជនជាប់ចោទយល់ថាខ្លួនពុំទាន់មានពេលគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន អាចធ្វើការសុំរយៈពេលបន្ថែម ឬក្នុងករណីដែលតុលាការយល់ឃើញថាអង្គហេតុនោះនៅមិនទាន់អាចជំនុំជម្រះបាន តុលាការអាចលើកសវនាការនៅពេលក្រោយបាន។ នៅក្នុងករណីនេះ តុលាការអាចធ្វើការបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយចេញសាលក្រមមានបញ្ជាក់ពីសំអាងហេតុ ដែលជាមូលហេតុចាំបាច់មាន ជាអាទិ៍៖[92]

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ (ជននោះអាចរត់គេចខ្លួន) ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គ្រាន់តែមានអានុភាពទៅលើជនជាប់ចោទប៉ុណ្ណោះ ជាហេតុនាំឱ្យតុលាការត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដើម្បីធ្វើការបញ្ជាឱ្យដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និង

[91] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៣០៥។

[92] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៥។

ឱ្យឃុំខ្លួនជនត្រូវចោទនោះ។[93] គិតចាប់ពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ តុលាការត្រូវប្រកាសសាលក្រម លើអង្គសេចក្តីក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍។ ប្រសិនបើ ពុំនោះទេការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ចប់ដោយពេញច្បាប់ ហើយជនជាប់ចោទត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ ព្រោះវិធានការនៃការឃុំខ្លួនបណ្តោះអាសន្ន ជាការប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពរបស់បុគ្គលដែលត្រូវបានធានា ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយម្យ៉ាងទៀត ជននេះមិនទាន់ត្រូវបានផ្តន្ទាទោសដោយតុលាការទេ។

**៣.៣.៣.អានុភាពនៃការបង្ហាញខ្លួនភ្លាម**

ប្រសិនបើ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម អានុភាពនឹងកើតឡើងតាមកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមដូចជាៈ ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចទៅតុលាការ និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល។

**ការផ្តាច់អាជ្ញាយុកាលនៃបទល្មើសៈ** ការចេញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដោយព្រះរាជអាជ្ញា គឺជាកិច្ចចោទប្រកាន់ទៅលើជនល្មើស។ ចំពោះកិច្ចចោទប្រកាន់មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ។ មូលហេតុ ដែលនាំឱ្យមានការផ្តាច់អាជ្ញាយុកាល គឺដូចគ្នានឹងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែរ។

**ការផ្ទេរសមត្ថកិច្ចតុលាការៈ** ការផ្ទេរសមត្ថកិច្ចពីអយ្យការ មកយុត្តាធិការជំនុំជម្រះតាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា តុលាការនឹងគ្មានសមត្ថកិច្ចលើការជំនុំជម្រះទេ ប្រសិនបើមិនមានកិច្ចចោទប្រកាន់មកខ្លួន។

**ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គលៈ** កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់ពីអង្គហេតុ និងពីបុគ្គលដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅលើបុគ្គលនោះ។ តុលាការអាចជំនុំជម្រះបានតែលើអង្គហេតុណាដែលមានចែងក្នុងកំណត់ហេតុនោះ ហើយអាចជំនុំជម្រះតែលើជនណាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែប៉ុណ្ណោះ។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២០។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីនាងខ្ញុំទាំងពីររូប បានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី **“ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា”** រួចមក នាងខ្ញុំទាំងពីរអាចទាញសេចក្តីសន្និដ្ឋានបានថា ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូង ពិតជាមានសារៈសំខាន់ណាស់ ចំពោះដំណើរនៃការស្វែងយល់អំពីនីតិវិធីព្រហ្មទណ្ឌ ដោយសារតែដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលស្មុគស្មាញ ក៏ដូចជាមានការស៊ើបអង្កេត និងស្វែងយល់អំពីធាតុផ្សំនៃបទល្មើសមុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងតុកតតចាត់ការ ដែលទាក់ទងទៅនឹងអង្គហេតុដែលកើតមានឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ អំណាចរបស់ព្រះរាជអាជ្ញានៅក្នុងដំណាក់កាលចោទប្រកាន់ គឺមានកំណត់នៅក្នុងច្បាប់ ពោលគឺមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧។

នៅក្នុងរឿងក្តីព្រហ្មទណ្ឌតួនាទីរបស់អង្គការអយ្យការ គឺជាដំណាក់កាល មួយនៅក្នុងការចោទប្រកាន់ ពីព្រោះ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ប៉ុន្តែ ដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជម្រើសនៃការចោទប្រកាន់ដល់ព្រះរាជអាជ្ញា ដោយសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ដូចនេះ នាំឱ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាន់យកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ មានន័យថា ទោះបីជាអំពើមួយជាបទល្មើសក៏ដោយ ប្រសិនបើពុំមានផលប្រយោជន៍ក្នុងការចោទប្រកាន់នោះទេ អាចនាំឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ ហេតុនេះខុសពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាមិនអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានទេ គឺនៅពេលដែលមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើងនោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ជាដាច់ខាត។ ទៀតសោត គោលការណ៍នីត្យានុកូលភាព គឺមានន័យថា មានតែអំពើដែលបង្កើតបានជាបទល្មើសនៅពេលដែលអំពើនោះ មានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ហើយមានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន។

លើសពីនេះទៅទៀត ការចោទប្រកាន់ត្រូវបានធ្វើឡើង បន្ទាប់ពីព្រះរាជអាជ្ញាទទួលបាននូវពាក្យប្តឹង និងពាក្យបរិហារដែលទាក់ទងទៅនឹងរឿងក្តីនៃបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយត្រូវបានទទួលដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ព្រមទាំងបុគ្គលដទៃផ្សេងទៀតក្រៅពីជនរងគ្រោះ ឬដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបញ្ជូនមកព្រះរាជអាជ្ញា។ នៅក្នុងនោះ ព្រះរាជអាជ្ញា ដែលជាម្ចាស់បណ្តឹងអាជ្ញា តែងតែប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួនក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍ទូទៅ ដូចនេះព្រះរាជអាជ្ញាមិនអាចបដិសេធសំណុំរឿងណាមួយដោយមិនធ្វើការចោទប្រកាន់នោះទេ ប្រសិនបើសំណុំរឿងនោះមានធាតុផ្សំ

នៃបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់ (ធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈ និងធាតុផ្សំអត្តនោម័ត) ហើយត្រូវបានរកឃើញថាមានអត្ថិភាពនៃបទល្មើស និងជនល្មើសមានពិរុទ្ធភាព ហើយមានស្ថានភាពចាំបាច់ដើម្បីសម្រេចធ្វើការចោទប្រកាន់។ តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមនីតិវិធី ៣ យ៉ាងគឺៈ ការចោទប្រកាន់តាមរយៈបើកការស៊ើបសួរ ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការចោទប្រកាន់តាមរយៈការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

សរុបសេចក្តីមក ចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូង ពិតជាមានសារៈសំខាន់នៅក្នុងដំណាក់កាលចោទប្រកាន់ចំពោះរឿងក្តីព្រហ្មទណ្ឌ ដោយបំពេញតួនាទីរបស់ខ្លួននៅក្នុងការស៊ើបអង្កេតទាក់ទងទៅនឹងអង្គហេតុដែលកើតមានឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងស្វែងយល់អំពីធាតុផ្សំនៃបទល្មើសមុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។

# អនុសាសន៍

ដោយឆ្លងតាមការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនេះ តាំងពីដើមរហូតមកដល់ចំណុចនេះ នាងខ្ញុំទាំងពីររូបសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

– ត្រូវបន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយស្ដីអំពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែប្រសើរ
– ត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចូលរួមក្នុងការសហការណ៍ ក៏ដូចជាការផ្ដល់នូវការពិតចំពោះអ្វីដែលពួកគាត់បានឃើញ ដឹង និងពាក់ព័ន្ធនឹងការពិតនៃសំណុំរឿង
– ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវរាល់កិច្ចចោទប្រកាន់ និងគោរពបទប្បញ្ញត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងនាមជាអ្នកស្វែងរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ
– ត្រូវផ្ដល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋស្របតាមអភិក្រមបួនរួមមាន លឿនរហ័ស ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ
– តំណាងអយ្យការត្រូវជៀសវាងឱ្យបាននូវអគតិធម៌ ៤ រួមមាន៖ ឆន្ទាគតិ (លម្អៀងព្រោះសេចក្ដីស្រឡាញ់) ទោសាគតិ (លម្អៀងព្រោះស្អប់) ភយាគតិ (លម្អៀងព្រោះខ្លាច) មោហាគតិ (លម្អៀងព្រោះល្ងង់ខ្លៅគឺ អវិជ្ជា) ហើយតំណាងអយ្យការត្រូវប្រកាន់ខ្ជាប់នូវសុគតិធម៌ ៥ រួមមាន៖ វិរិយសម្បយុត្តសុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ និងបញ្ញាវុធវិនិច្ឆ័យ
– ត្រូវបង្កើតឱ្យមានមន្ទីរពិសោធន៍មួយនៅតាមសាលាដំបូងរាជធានី-ខេត្ត ដោយមានអ្នកជំនាញនៅប្រចាំការធ្វើការ និងបំពាក់នូវឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ ដើម្បីសម្រួលដល់ការពិនិត្យធ្វើកោសលវិច័យទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដោយកត្តានេះអាចជួយពន្លឿនក្នុងការស្រាវជ្រាវមួយកម្រិតផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, នស/រកម/០៧១៦/០០៩, ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១៦។
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧, ១៦ កក្កដា ឆ្នាំ២០១៤។
- ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤។
- ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ, នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤។
- ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, នស/រកម/១០០៥/០៣១, ២៤ តុលា ឆ្នាំ២០០៥។

## ២. សៀវភៅ និងស្នាដៃនិពន្ធ

- ព្រឹត្តិបត្រច្បាប់សាលាត្រាជូ, ស្តីពី ការចោទប្រកាន់បីរបៀបរបស់ព្រះរាជអាជ្ញា, ដោយលោក ចក សម្បត្តិ, លេខទី៤, ខែមករា ឆ្នាំ២០២៣។
- សៀវភៅមេរៀនស្តីពី នីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ឆ្នាំ២០២២។
- សៀវភៅមេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ និងព្រហ្មទណ្ឌពិសេសដោយលោកសាស្ត្រាចារ្យ មីន សំអុល, ឆ្នាំ២០២០-២០២១។

## ៣. គេហទំព័រ

- សមាគមសាលាត្រាជូ, http://salatraju.com/post/406 (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣)។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | ទម្រង់នៃដីកាចាត់តាំងតំណាងអយ្យការ |
| ឧបសម្ព័ន្ធទី២ | ទម្រង់នៃដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ |
| ឧបសម្ព័ន្ធទី៣ | ទម្រង់នៃដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន ឬរុករកវត្ថុតាង |
| ឧបសម្ព័ន្ធទី៤ | ទម្រង់នៃកំណត់ហេតុទទួលវត្ថុតាង |
| ឧបសម្ព័ន្ធទី៥ | ទម្រង់នៃដីកាបង្គាប់ឱ្យតម្កល់ទុកវត្ថុតាង |
| ឧបសម្ព័ន្ធទី៦ | ទម្រង់នៃដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ |
| ឧបសម្ព័ន្ធទី៧ | ទម្រង់នៃលិខិតជូនដំណឹង |
| ឧបសម្ព័ន្ធទី៨ | ទម្រង់នៃដីកាសម្រេចរំលត់បណ្តឹងអាជ្ញា |
| ឧបសម្ព័ន្ធទី៩ | ទម្រង់នៃដីកាកោះ |
| ឧបសម្ព័ន្ធទី១០ | ទម្រង់នៃដីកាបង្គាប់ឱ្យចូលខ្លួន |
| ឧបសម្ព័ន្ធទី១១ | ទម្រង់នៃដីកាបង្គាប់ឱ្យចាប់ខ្លួន |
| ឧបសម្ព័ន្ធទី១២ | ទម្រង់នៃដីកាបញ្ជូប់ឱ្យចាប់ខ្លួន |
| ឧបសម្ព័ន្ធទី១៣ | ទម្រង់នៃដីកាបង្គាប់ឱ្យនាំខ្លួន |
| ឧបសម្ព័ន្ធទី១៤ | ទម្រង់នៃដីកាបញ្ជូប់ឱ្យនាំខ្លួន |
| ឧបសម្ព័ន្ធទី១៥ | ទម្រង់នៃដីកាអញ្ជើញមេធាវី ឬអ្នកជំនាញ |
| ឧបសម្ព័ន្ធទី១៦ | ទម្រង់នៃដីកាទទួលយកមេធាវីឱ្យការពារកូនក្តី |
| ឧបសម្ព័ន្ធទី១៧ | ទម្រង់នៃដីកាចាត់តាំងអ្នកជំនាញ |
| ឧបសម្ព័ន្ធទី១៨ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| ឧបសម្ព័ន្ធទី១៩ | ទម្រង់នៃដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែម |
| ឧបសម្ព័ន្ធទី២០ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបទល្មើសថ្មីបន្ថែម |
| ឧបសម្ព័ន្ធទី២១ | ទម្រង់នៃដីកាផ្ទេរសមត្ថកិច្ច |
| ឧបសម្ព័ន្ធទី២២ | ទម្រង់នៃដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ |
| ឧបសម្ព័ន្ធទី២៣ | ទម្រង់នៃដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះភ្លាម |
| ឧបសម្ព័ន្ធទី២៤ | ទម្រង់នៃដីកាសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌ |
| ឧបសម្ព័ន្ធទី២៥ | ទម្រង់នៃដីកាសម្រេចបំបែកសំណុំរឿង |
| ឧបសម្ព័ន្ធទី២៦ | ទម្រង់នៃដីកាសន្និដ្ឋានស្ពាពរ |

ឧបសម្ព័ន្ធទី១

# ព្រះរាជាណាចក្រកម្ពុជា

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ********

..........................

*********

លេខ........................

# ដីកាចាត់តាំងតំណាងអយ្យការ

************

យើង.................................................... ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង .................................................. ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ..........................អក. ចុះថ្ងៃទី........... ខែ......................... ឆ្នាំ....................... របស់អយ្យការអមតុលាការខេត្ត-ក្រុង ..........................................................។

បានឃើញ (១) ..........................................................................លេខ .............................. ចុះថ្ងៃទី ...................... ខែ .......................... ឆ្នាំ ....................... របស់ .......................................................................................................

ដែលមានវិមតិសង្ស័យលើ :

ឈ្មោះ (២) ................................................ភេទ ......................អាយុ ...........................ឆ្នាំ ។

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

បានប្រព្រឹត្តពីបទ: .................................................................................................................

នៅភូមិ ............................ឃុំ-សង្កាត់ ............................. ស្រុក-ខណ្ឌ .......................... ខេត្ត-ក្រុង ...............................

កាលពីថ្ងៃទី ............................ ខែ ............................. ឆ្នាំ ............................... ។

ចាត់តាំងលោក ........................................................................ ជាតំណាងអយ្យការដើម្បីចាត់ការសំណុំរឿងព្រហ្មទណ្ឌខាងលើនេះតាមច្បាប់ ។

ធ្វើនៅ............................ ថ្ងៃទី.......... ខែ................. ឆ្នាំ........

**ព្រះរាជអាជ្ញា**

---

**កំណត់សំគាល់** : ដីកានេះ យកលេខចេញពីសៀវភៅពិសេសរបស់អយ្យការ ។

(១). របាយការណ៍បញ្ជូនសំណុំរឿងរបស់នគរបាលយុត្តិធម៌ ឬពាក្យបណ្តឹងរបស់ជនរងគ្រោះផ្ទាល់ ។

(២). បើជនល្មើសច្រើននាក់ ត្រូវសរសេរឈ្មោះ ភេទ និងអាយុគ្រប់ជនល្មើសទាំងអស់ ។

ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ***********

....................................

*********** **ដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ**

លេខ...................... **********

យើង .......................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង .......................................

បានឃើញ មាត្រា ៩៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

បានឃើញ [១] ..........................................................................................................................

..........................................................................................................................................

..........................................................................................................................................

យល់ឃើញថា [២] ...................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ហេតុដូច្នេះ សម្រេច**

១. បង្គាប់មកលោក ........................................... ជាមន្ត្រីនគរបាលយុត្តិធម៌ ដឹកនាំកម្លាំងចុះពិនិត្យទីកន្លែងកើតហេតុនៅចំណុច ............................................................................ ដែលស្ថិតនៅភូមិ ................................ ឃុំ-សង្កាត់ ............................ ស្រុក-ខណ្ឌ .................................... ខេត្ត-ក្រុង ............................................. នៅថ្ងៃទី ............... ខែ ....................... ឆ្នាំ ..................... វេលាម៉ោង .......................................................។

២. ក្រោយពីបានចុះពិនិត្យទីកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូន ក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួន ព្រមទាំងវត្ថុតាង ប្រសិនបើមានមកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង .......................................... ដើម្បីចាត់ការតាមច្បាប់។

ធ្វើនៅ.......................... ថ្ងៃទី.......... ខែ.................... ឆ្នាំ.........

**ព្រះរាជអាជ្ញា**

---

កំណត់សំគាល់: ១. សរសេរចុះ ពត៌មាន ពាក្យបណ្តឹង ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

២. សរសេរចុះអំពីវិធានការស៊ើបអង្កេត ដែលជាវិធានចាំបាច់ក្នុងការស្វែងរកឱ្យឃើញនូវការពិត ដើម្បីបង្ក្រាបបទល្មើស។

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ************

................................ **ដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន**

*********** **ឬ រុករកវត្ថុតាង**[១]

លេខ.......................... *********

យើង .......................................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង..........................................

បានឃើញ ...........................................................................................................................................

.......................................................................................................................................................................

បានឃើញ ...........................................................................................................................................

.......................................................................................................................................................................

បានឃើញ ...........................................................................................................................................

.......................................................................................................................................................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ............. ចុះថ្ងៃទី.......... ខែ......................... ឆ្នាំ......................... ។

យល់ឃើញថា: ......................................................................................................................................

.......................................................................................................................................................................

.......................................................................................................................................................................

.......................................................................................................................................................................

.......................................................................................................................................................................

## ហេតុដូច្នេះ សម្រេច

១. បង្គាប់មកលោក ...................................................... ជា ...................................................................... ដើម្បីចាត់ចែងចុះឆែកឆេរលំនៅដ្ឋាន ឬរុករកវត្ថុតាងនៅចំណុច[២] ....................................... របស់ឈ្មោះ ................................ ដែលស្ថិតនៅភូមិ .......................................ឃុំ-សង្កាត់ ...................................... ស្រុក-ខណ្ឌ ........................................ ខេត្ត-ក្រុង .......................................................។

២. ក្រោយពីបានចុះឆែកឆេរ ឬរុករកវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួនព្រមទាំងវត្ថុតាង ប្រសិនបើមានមកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ........................................ ដើម្បីចាត់ការតាមច្បាប់។

ធ្វើនៅ.................... ថ្ងៃទី........... ខែ .................. ឆ្នាំ.................

**ព្រះរាជអាជ្ញា**

---

**កំណត់សំគាល់:** (១).ព្រះរាជអាជ្ញាអាចចេញដីកានេះបាន លុះត្រាតែសំណុំរឿងមិនទាន់បានបញ្ជូនទៅចៅក្រមស៊ើបអង្កេត "មាត្រា ៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ" ។

(២).បញ្ជាក់ឱ្យបានច្បាស់អំពីអាស័យដ្ឋាន និងឈ្មោះដែលត្រូវឆែកឆេរ ឬរុករកវត្ថុតាង ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

# កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់....................................ខែ............................ថ្ងៃទី........................................................ វេលាម៉ោង................................................. ។

យើង..........................................ក្រឡាបញ្ជីនៃអយ្យការអមតុលាការខេត្ត-ក្រុង................................. ជាអ្នកទទួល ។

លោក ....................................... ជាភ្នាក់ងារនៃមន្ទីរនគរបាលយុត្តិធម៌......................ឃុំ-សង្កាត់........... .....................ស្រុក-ខណ្ឌ ......................... ខេត្ត-ក្រុង ........................... រួមជាមួយឈ្មោះ ............................ ជាជនល្មើស និងឈ្មោះ ................................. ជាដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ឬតំណាងជនរងគ្រោះ ព្រមទាំងឈ្មោះ ............................... ជាអ្នកជំនាញខាង ....................................................................................... ។

បានពិនិត្យភិនភាគវត្ថុតាងដែលទាក់ទងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ........................ ចុះថ្ងៃទី ................. ខែ ................................... ឆ្នាំ ........................................................ ឃើញដូចខាងក្រោមៈ

១/...........................................................................................................................

២/...........................................................................................................................

៣/...........................................................................................................................

យើងធ្វើកំណត់ហេតុនេះទុកជាសំគាល់ដើម្បីធានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ...................... ចុះថ្ងៃទី.......... ខែ.................. ឆ្នាំ...................... តាមផ្លូវច្បាប់តទៅ ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ...........................នាថ្ងៃខែឆ្នាំដូចខាងលើ ។

| | | | | |
|---|---|---|---|---|
| ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ។ | ជនល្មើស | អ្នកជំនាញ | អ្នកប្រគល់ | អ្នកទទួល |

បានឃើញ

ថ្ងៃ.............. ខែ................. ឆ្នាំ................

**ព្រះរាជអាជ្ញា "តំណាងអយ្យការក៏បាន"**

ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង *********

............................

********* 

# ដីកាបង្គាប់ឱ្យដឹកលំនុកវត្ថុតាង

លេខ....................... **********

យើង........................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ..................................... ។

បង្គាប់មកលោក ....................................ក្រឡាបញ្ជីនៃអយ្យការអមតុលាការខេត្ត-ក្រុង ......................... ឱ្យទទួលតម្កល់ទុកនូវវត្ថុតាងដូចមានបញ្ជីភ្ជាប់ជាមួយនេះ ដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ............................ ចុះថ្ងៃទី............. ខែ .................. ឆ្នាំ ................. និងសំណុំរឿងស៊ើបសួរលេខ................ ចុះថ្ងៃទី .................. ខែ ...................... ឆ្នាំ ...................... ។

**ចេញពីប្រភពៈ**- នគរបាលយុត្តិធម៌ .......................................................................................................

- អាវុធហត្ថ .................................................................................................................
- អយ្យការអមតុលាការ ខេត្ត-ក្រុង ..............................................................................
- ចៅក្រមស៊ើបអង្កេតនៃ តុលាការខេត្ត-ក្រុង ..................................................................
- តុលាការជាន់ខ្ពស់ ......................................................................................................

ធ្វើនៅ............................................ ថ្ងៃទី............. ខែ............... ឆ្នាំ ...............

**ព្រះរាជអាជ្ញា**

ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ********

..........................

*********

លេខ........................

## ដីកាសម្រេចដំកល់រឿងទុកឥតចាត់ការ [១]

************

យើង.................................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង........................................... ។

បានឃើញ [២] ...............................................................................................................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ................................ចុះថ្ងៃទី............ ខែ.......................... ឆ្នាំ........................ ដែលមានដំណើររឿងដូចតទៅ: .................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

បានឃើញ [៣] ...............................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់:

យល់ឃើញថា [៤] ..........................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

### ហេតុដូច្នេះ សម្រេច

១- តម្កល់រឿងនេះទុកឥតចាត់ការ ។

២- បង្គាប់ឱ្យក្រឡាបញ្ជីជូនដំណឹងទៅឈ្មោះ............................................. ត្រូវជា............................................. ដើម្បីជ្រាប ។

ធ្វើនៅ............................ ថ្ងៃទី.......... ខែ................. ឆ្នាំ........

**ព្រះរាជអាជ្ញា**

---

**កំណត់សំគាល់** (១). ដីកាសម្រេចនេះគ្មានអាជ្ញាជាសេចក្ដីសម្រេចដាច់ខាតនៅឡើយទេ អាចប្រែប្រួលបានកុំឱ្យតែបណ្ដឹងអាជ្ញាត្រូវរលត់ ដោយផុតអាជ្ញាយុកាល ។

(២). សំរាប់សរសេរចុះ ឯកសារ និងភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថា អំពើនោះមិនចូលជាបទល្មើសព្រហ្មទណ្ឌ។

(៣). អំពើដែលប្ដឹងមកនោះមិនចូលជាបទល្មើសព្រហ្មទណ្ឌ។

ឧបសម្ព័ន្ធទី៧

# ព្រះរាជាណាចក្រកម្ពុជា

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ********

...........................

*********

# លិខិតជូនដំណឹង

លេខ.........................

**********

យើង ...............................................តំណាងអយ្យការអមតុលាការខេត្ត-ក្រុង .....................................

ជម្រាបមកលោក-លោកស្រី ............................................. ទីលំនៅភូមិ ...........................................................

ឃុំ-សង្កាត់ ....................................... ស្រុក-ខណ្ឌ ....................................... ខេត្ត-ក្រុង ............................. ។

ត្បិតពាក្យបណ្តឹងចុះថ្ងៃទី ................ ខែ .................. ឆ្នាំ .................. របស់លោក លោកស្រី ដែលបានប្តឹង

ពីឈ្មោះ ....................................... ទីលំនៅភូមិ ........................................ ឃុំ-សង្កាត់ ..................................

ស្រុក-ខណ្ឌ ................................... ខេត្ត-ក្រុង .......................................... ពីបទ ..........................................

ប្រព្រឹត្តនៅភូមិ ................................. ឃុំ-សង្កាត់ ..................................... ស្រុក-ខណ្ឌ .................................

ខេត្ត-ក្រុង ....................................... កាលពីថ្ងៃទី ................... ខែ ............................ ឆ្នាំ ............................

តាមមាត្រា ........................................ នៃច្បាប់ ................................................................................................

នោះយើងបានសម្រេច .............................................................................................................................................

.............................................................................................................................................................................

លោក-លោកស្រី មានសិទ្ធិប្តឹងឧទ្ធរណ៍នឹង...............................................................................................

គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះតទៅ ។

ធ្វើនៅ................................. ថ្ងៃទី........... ខែ .....................ឆ្នាំ ..................

**ព្រះរាជអាជ្ញា**

យើង..............................................................................................................................................

បានប្រគល់លិខិតជូនដំណឹងនេះដល់ឈ្មោះ ........................................... ទីលំនៅសព្វថ្ងៃនៅភូមិ................................

ឃុំ-សង្កាត់ ..................................... ស្រុក-ខណ្ឌ ..........................................ខេត្ត-ក្រុង...................................

នៅថ្ងៃទី .............. ខែ...................... ឆ្នាំ.............. ហើយបានប្រាប់ថាបើមិនសុខចិត្តនឹង.......................................

...........................................................................................................................របស់តំណាងអយ្យការ

នេះទេ ត្រូវចូលទៅប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**អ្នកទទួល** **អ្នកប្រគល់**

ហត្ថលេខា ឬផ្តិតមេដៃ

ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ********

........................ **ដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា**

******** **************

លេខ..........................

យើង............................................ តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ......................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ................................. ចុះថ្ងៃទី............ ខែ...................ឆ្នាំ.................

បានឃើញសំណុំរឿងស៊ើបសួរលេខ............................... ចុះថ្ងៃទី.............. ខែ................. ឆ្នាំ................

បានឃើញដីកាជូនរឿងមូលទៅពិនិត្យលេខ ...................... ចុះថ្ងៃទី ............ ខែ ............... ឆ្នាំ ................

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់យល់ឃើញថា: ..........................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**<u>ហេតុដូច្នេះ សម្រេច</u>**

១- រំលត់បណ្ដឹងអាជ្ញាលើឈ្មោះ .....................................ភេទ............ អាយុ .............ឆ្នាំ ជាតិ............ របររកស៊ី........................................ ទីលំនៅបច្ចុប្បន្ននៅភូមិ...........................ឃុំ-សង្កាត់.................................. ស្រុក-ខណ្ឌ................................................ខេត្ត-ក្រុង.......................................ទោសពីមុន ........................... និងគូកន ។ ឪពុកឈ្មោះ............................................ "រ-ស" ម្ដាយឈ្មោះ ........................................ "រ-ស" ប្ដីឬប្រពន្ធឈ្មោះ...................................................."រ-ស"មានកូន ឬនៅលីវ ..........................................នាក់ ពីបទ......................................................................................... ប្រព្រឹត្តនៅភូមិ........................................................ ឃុំ-សង្កាត់............................. ស្រុក-ខណ្ឌ................................. ខេត្ត-ក្រុង............................................កាលពី ថ្ងៃទី .......... ខែ ................. ឆ្នាំ ..................... តាមមាត្រា.................................................................. នៃច្បាប់ ..........................................................................................................................................................។

២- បញ្ជូនសំណុំរឿង និងវត្ថុតាង ព្រមទាំងភស្តុតាងនានា ទៅតុលាការ ដើម្បីជំនុំជម្រះសម្រេចសេចក្ដី អំពីសំណង និងជំងឺចិត្ត ដល់ជនរងគ្រោះតាមច្បាប់ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងសុំ។

ធ្វើនៅ............................. ថ្ងៃទី......... ខែ................. ឆ្នាំ...................

**ព្រះរាជអាជ្ញា**

ឧបសម្ព័ន្ធទី៩

# ព្រះរាជាណាចក្រកម្ពុជា

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង **********

................................. **ដីកាកោះ**

********* ******

លេខ: ......................

សំណុំរឿងព្រហ្មទណ្ឌលេខ ...................

ចុះថ្ងៃទី .......... ខែ ............. ឆ្នាំ ........

យើង...............................................តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ..................................... អញ្ជើញឈ្មោះ ............................................... ជា.........................................................ទីលំនៅបច្ចុប្បន្ននៅ ភូមិ .................... ឃុំ-សង្កាត់ ................................ ស្រុក-ខណ្ឌ ............................... ខេត្ត-ក្រុង ...................... ឱ្យចូលទៅកាន់អយ្យការអមតុលាការខេត្ត-ក្រុង..................................... នៅវេលាម៉ោង ..................................... ថ្ងៃទី............. ខែ...................ឆ្នាំ...................... ។

ដើម្បី......................................................................................................................................................
.........................................................................................................................................................
....................................................................................................................................................... ។

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ........................... ថ្ងៃទី...............ខែ................ ឆ្នាំ.............

**ព្រះរាជអាជ្ញា**

យើង.................................................................................................................................

បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ ...............................................................................................................

ទីលំនៅបច្ចុប្បន្ននៅភូមិ.......................... ឃុំ-សង្កាត់...................................ស្រុក-ខណ្ឌ...............................

ខេត្ត-ក្រុង ............................ នៅថ្ងៃទី................ ខែ.............. ឆ្នាំ..................... ហើយយើងបានប្រាប់ថា សាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខអយ្យការអមតុលាការ ខេត្ត-ក្រុង .................................... ។

***អ្នកទទួល***

ហត្ថលេខា ឬផ្តិតមេដៃ

***អ្នកប្រគល់***

ហត្ថលេខា

---

**<u>កំណត់សំគាល់:</u>** អ្នកប្រគល់ដីកានេះ ក្រោយពីអ្នកទទួលដីកាបានចុះហត្ថលេខា ឬផ្តិតមេដៃលើដីកាទាំងពីរសន្លឹករួច ហើយត្រូវប្រគល់សន្លឹក "ចុងដីកា" ទៅឱ្យអ្នកទទួល និងបង្វិលសន្លឹក "ដើមដីកា" ទៅអយ្យការអមតុលាការខេត្ត-ក្រុងវិញឱ្យបានមុនថ្ងៃកំណត់ក្នុងដីកា ។

ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**********

**អយ្យការអម**

តុលាការខេត្ត-ក្រុង

............................

*********

# ដីកាបង្គាប់ឱ្យចូលខ្លួន(១)

********

លេខ ......................

យើង ................................................ តំណាងអយ្យការអម តុលាការខេត្ត-ក្រុង .............................. ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .................. ចុះថ្ងៃទី ............. ខែ ................... ឆ្នាំ...................... ។

បានឃើញដីកាកោះលេខ.............. ចុះថ្ងៃទី .......... ខែ ............ឆ្នាំ ................ ដែលតំណាងអយ្យការបានចាត់ការតាមនីតិវិធីត្រឹមត្រូវរួចហើយ ប៉ុន្តែឈ្មោះនេះ មិនព្រមចូលខ្លួនមកបំភ្លឺនៅចំពោះមុខអយ្យការតាមកាលកំណត់ទេ។

បង្គាប់មកឈ្មោះ ...................................... ភេទ.............. អាយុ ........... ឆ្នាំ ជាតិ ............................ ទីលំនៅបច្ចុប្បន្ន នៅភូមិ........................ឃុំ-សង្កាត់ ................................. ស្រុក-ខណ្ឌ ...................................... ខេត្ត-ក្រុង .............................................ឱ្យចូលខ្លួនទៅកាន់អយ្យការអមតុលាការ ខេត្ត-ក្រុង ............................ នៅថ្ងៃទី............................ ខែ .............................. ឆ្នាំ ............................ វេលាម៉ោង .................................. ដើម្បី ..................................................................................................................................................... ............................................................................................................................................................ ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ *<u>យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន</u>* ។

ធ្វើនៅ........................ ថ្ងៃទី......... ខែ.......... ឆ្នាំ .............

**ព្រះរាជអាជ្ញា**

យើង....................................... ជា ..........................................................................................

បានប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួននេះដល់ឈ្មោះ.........................................ទីលំនៅបច្ចុប្បន្ននៅភូមិ...............

ឃុំ-សង្កាត់ ..........................ស្រុក-ខណ្ឌ ................................ ខេត្ត-ក្រុង .....................................

នៅថ្ងៃទី ....................... ខែ ............................... ឆ្នាំ .......................... ហើយយើងបានប្រាប់ថា

ឱ្យយកចុងដីកានេះទៅប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខអយ្យការអមតុលាការខេត្ត-

ក្រុង .................................................... ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។

| **អ្នកទទួល** | **អ្នកប្រគល់** |
|---|---|
| ហត្ថលេខា ឬ ស្នាមមេដៃ | ហត្ថលេខា |

---

***កំណត់សំគាល់:*** "១" អ្នកប្រគល់ដីការនេះ ក្រោយពីអ្នកទទួលដីកា បានចុះហត្ថលេខា ឬផ្តិតមេដៃលើដីកាទាំងពីរសន្លឹករួចហើយ ត្រូវប្រគល់សន្លឹក "ចុងដីកា" ទៅឱ្យអ្នកទទួល និងបង្វិលសន្លឹក "ដើមដីកា" ទៅអយ្យការអមតុលាការខេត្ត-ក្រុងវិញឱ្យបានមុនថ្ងៃកំណត់ក្នុងដីកា។

**ព្រះរាជាណាចក្រកម្ពុជា**

អយ្យការអម　　　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង　　　　　　　　*********

..........................

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

លេខ..................　　　　　　　********

យើង.............................................តំណាងអយ្យការអមតុលាការខេត្ត-ក្រុង............................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ........................... ចុះថ្ងៃទី...........ខែ..............ឆ្នាំ...............................។

បានឃើញ.....................................................................................................................................................

.....................................................................................................................................................................

.....................................................................................................................................................................

....................................................................................................................................................................។

យល់ឃើញថា:-

ឈ្មោះ.......................................................... ភេទ........... អាយុ.............ឆ្នាំ ជាតិ...........................................

របររកស៊ី...................................... កើតនៅភូមិ...............................ឃុំ-សង្កាត់.....................................................

ស្រុក-ខណ្ឌ...................................... ខេត្ត-ក្រុង................................ ។ ទីលំនៅបច្ចុប្បន្នភូមិ............................................

ឃុំ-សង្កាត់..............................ស្រុកខណ្ឌ............................ ខេត្ត-ក្រុង............................ ទោសពីមុន.........................។

ឪពុកឈ្មោះ........................................................"រ-ស" ម្តាយឈ្មោះ.................................................................."រ-ស"

ប្តីឬប្រពន្ធឈ្មោះ..............................."រ-ស"មានកូនឬនៅលីវ....................................។

